ឆ្នាំគ្រួសារ ២០១៧-២០២០

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែកញ្ញា ឆ្នាំ២០១៨ លក់តម្លៃ ១០០០រៀល

លេខ ១១៤



Photo : Ritty Rath

## គ្រីស្តបរិស័ទអធិដ្ឋានឧទ្ទិសដល់វិញ្ញាណក្ខន្ធទាំងឡាយ

Formation, Dailouge, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org

Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org

https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

ចាងហ្វាង : លោក លី សុវណ្ណា

សេចក្តីប្រកាសលេខ៖ ០២០/១៨ ព.ម.រ.ល.អ/ ០១-មករា-២០១៨

# ធនាគារអភិវឌ្ឍន៍អាស៊ី ថា កំណើនសេដ្ឋកិច្ចកម្ពុជានៅតែប្រសើរ



ថតដោយ: លី សុវណ្ណា

ធនាគារអភិវឌ្ឍន៍អាស៊ី (ហៅកាត់ថា ADB) បានព្យាករណ៍ថា ផលិតផលក្នុងស្រុកសរុប (ផ.ស.ស) របស់ប្រទេសកម្ពុជា នឹងបន្តរក្សាកំណើនរឹងមាំ ក្នុងឆ្នាំ ២០១៨ ជាមួយនឹងការរំពឹងទុកថា ការនាំចេញ និងការប្រើប្រាស់ក្នុងស្រុកនឹងមានលទ្ធផលល្អប្រសើរ។

ក្នុងការធ្វើបច្ចុប្បន្នភាពរបាយការណ៍ពិសេសរបស់ខ្លួន ដែលមានឈ្មោះថា ទស្សនវិស័យអភិវឌ្ឍន៍អាស៊ី (ADO) ឆ្នាំ ២០១៨ ADB ព្យាករណ៍ថា ប្រទេសកម្ពុជានឹងមានកំណើនសេដ្ឋកិច្ចប្រមាណ ៧,០% សម្រាប់ឆ្នាំ ២០១៨ និង២០១៩ ខណៈពេលដែលសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍភាគច្រើននៅអាស៊ី នៅបន្តកំណើនថេរ ហើយប្រទេសឧស្សាហកម្មធំៗមានភាពរឹងមាំកម្រិតមធ្យម។

លោកស្រី សានីញ៉ា ដូ៉រានី ចាម៉ាល់ នាយក ADB ប្រចាំប្រទេសកម្ពុជា មានប្រសាសន៍ថា "សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា បន្តកើនឡើង ក្នុងល្បឿនដ៏រឹងមាំ ដោយសារតែមានការជំរុញពីកំណើនការនាំចេញដ៏រឹងមាំ ការកើនឡើងនៃចំនួនភ្ញៀវទេសចរណ៍ តម្រូវការក្នុងស្រុកមានសន្ទុះខ្លាំងក្លា និងការពង្រីកគោលនយោបាយសារពើពន្ធ។ ប៉ុន្តែកំណើនប្រាក់ឈ្នួលដ៏ឆាបរហ័ស ដោយពុំមានកំណើនផលិតភាពអាចបង្កឱ្យមានហានិភ័យក្នុងស្រុកចម្បងមួយ ដែលអាចប៉ះពាល់ដល់សមត្ថភាពប្រកួតប្រជែងរបស់ប្រទេសកម្ពុជាជាមួយនឹងប្រទេសដទៃទៀតដែលបន្តពឹងអាស្រ័យលើកកម្លាំងពលកម្ម ដែលមានថ្លៃឈ្នួលទាប"។

ការនាំចេញទំនិញកើនឡើង ១៣,៣% ហើយការនាំចូលទំនិញ កើនឡើង ២៥,៧% ដោយសារតម្រូវការក្នុងស្រុកខ្ពស់ក្នុងឆមាសទីមួយ នៃឆ្នាំ២០១៨។ ឱនភាពគណនីចរន្ត ដោយមិនរាប់បញ្ចូលជំនួយឥតសំណងពីបរទេស ត្រូវបានរំពឹងថានឹងកើនឡើងដល់ ១២,១% នៃ ផ.ស.ស នៅឆ្នាំនេះ ពោលគឺកើនពី ១០,៩% ក្នុងឆ្នាំ ២០១៧ ប៉ុន្តែគេរំពឹងថា ឱនភាពនេះ នឹងថយចុះមកវិញ នៅឆ្នាំក្រោយ។ ទោះយ៉ាងណា ការព្យាករណ៍ចុងក្រោយនេះ នៅតែលើសកម្រិតព្យាករណ៍ក្នុងរបាយការណ៍ ADO កាលពីខែមេសា ដែលបានប៉ាន់ប្រមាណ ឱនភាពគណនីចរន្ត ក្នុងកម្រិត ១១,១% នៃ ផ.ស.ស ក្នុងឆ្នាំ ២០១៨ និង១០,៨% ក្នុងឆ្នាំ២០១៩។ វិស័យទេសចរណ៍ បានបន្តកើនឡើង ដែលមួយផ្នែកធំដោយសារកំណើនចំនួនភ្ញៀវទេសចរមកពីសាធារណរដ្ឋប្រជាមានិតចិន។

ជញ្ជីងទូទាត់ជារួម នឹងនៅបន្តរក្សាអតិរេក ដោយសារតែលំហូររឹងមាំនៃការវិនិយោគដោយផ្ទាល់ពីបរទេស ដែលនាំឱ្យមានការបន្តការកើនឡើងនូវទុនបម្រុងបរទេសបន្ថែមទៀត គឺពី៩,១ពាន់លានដុល្លារក្នុងខែកក្កដា ឆ្នាំ២០១៨ រហូតដល់ប្រមាណជា ១០ ពាន់លានដុល្លារ នៅចុងឆ្នាំ២០១៨ ដែលអាចរ៉ាប់រងចំណាយសម្រាប់ការនាំចូលបានរយៈពេល ៦ ខែ។

បើទោះជាកំណើនសេដ្ឋកិច្ចមានភាពរឹងមាំក៏ដោយ អត្រាអតិផរណាបានថមថយមកវិញ ដោយគិតជាមធ្យមស្ថិតក្នុងកម្រិត ២,៤% នៅក្នុងរយៈពេល ៦ ដំបូង ក្នុងឆ្នាំ ២០១៨ គឺថយចុះពី ៣,៤% រយៈពេលដូចគ្នាកាលពីឆ្នាំមុន ដោយសារតែកំណើនក្នុងកម្រិតទាបនៃតម្លៃស្បៀងអាហារ។ មានការព្យាករណ៍ថា អត្រាអតិផរណាគិតជាមធ្យម នឹងមានកម្រិត ២,៦% នៅឆ្នាំនេះ ហើយនឹងកើនឡើងដល់ប្រមាណ ៣,០% នៅឆ្នាំក្រោយ។

ការកើនឡើងនៃចំណាយរបស់រដ្ឋាភិបាល ដោយសារការបង្កើនការវិនិយោគសាធារណៈ និងបៀវត្សរ៍សម្រាប់វិស័យសាធារណៈ ក៏បានជួយរុញច្រានកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ ២០១៨ផងដែរ។ ចំណូលក្នុងរយៈពេល ប្រាំមួយខែដំបូង ក្នុងឆ្នាំ ២០១៨ ស្មើនឹង ៥៣,៣% នៃផែនការថវិកា សម្រាប់ឆ្នាំនេះ។ ក្នុងពេលជាមួយគ្នា ចំណាយមានត្រឹមតែ ៣៤,៥% តែប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ បទពិសោធកន្លងមកបង្ហាញថា ចំណាយមានការកើនឡើងនៅចុងឆ្នាំ។ គេរំពឹងថា ឱនភាពសារពើពន្ធនៅឆ្នាំនេះ នឹងកៀកទៅនឹងផែនការថវិកា ពោលគឺប្រហាក់ប្រហែលនឹង ៥,១% នៃ ផ.ស.ស។

ធនាគារអភិវឌ្ឍន៍អាស៊ីប្ដេជ្ញានាំមកនូវវិបុលភាព បរិយាប័ន្ន ភាពធន់ និងនិរន្តរភាពសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក ហើយក្នុងពេលជាមួយគ្នា នឹងបន្តរក្សាចីរភាពនៃកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការលុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ។ បង្កើតឡើងក្នុងឆ្នាំ ១៩៦៦ ធនាគារនេះគឺជាកម្មសិទ្ធិរបស់ប្រទេសជាសមាជិកចំនួន៦៨ ដែលក្នុងនោះមាន ៤៩ប្រទេស មកពីតំបន់នេះ។ ក្នុងឆ្នាំ២០១៧ ប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមានទឹកប្រាក់សរុប ៣២,២ ពាន់លានដុល្លារ ដែលក្នុងនោះ មាន១១,៩ ពាន់លានដុល្លារជាសហហិរញ្ញប្បទាន។

កាលពីដើមខែ កញ្ញា កន្លងទៅនេះ ស្ថាប័នវាយតម្លៃសេដ្ឋកិច្ចអាស៊ាន បូកបី ដែលមានមូលដ្ឋាន នៅប្រទេសសិង្ហបុរី បានវាយតម្លៃថា កំណើនសេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំនេះ គឺនៅក្នុងរង្វង់ ៧,២ ភាគរយ។

*ដោយ អរិយបុត្រ*

# ទម្លាប់ទាំង ៦ បំផ្លាញបេះដូងរបស់យើង



មានការសិក្សាមួយដែលផ្សព្វផ្សាយនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ នៅក្នុងឯកសារនៃ វេជ្ជសាស្ត្រផ្ទៃក្នុងនៅប្រទេសបារាំង ដែលធ្វើពិសោធន៍លើបុរស និងស្ត្រីចំនួន ៤៩០០នាក់ នៅចក្រភពអង់គ្លេស។ អ្នកសិក្សាស្រាវជ្រាវបានធ្វើជំរឿនអំពីទម្លាប់យ៉ាងហោចណាស់ទាំង៤ ដ៏អាក្រក់ ដូចជា ការជក់បារី បរិភោគបន្លែផ្លែឈើតិចតួច ធ្វើសកម្មភាពរាងកាយតិចតួច និងបរិភោគគ្រឿងស្រវឹងលើសលុប ដែលអាចបំផ្លាញបេះដូង។ បើប្រៀបធៀបនឹងអ្នកចូលរួមដែលមិនមានទម្លាប់នេះណាមួយ អ្នកដែលមានទម្លាប់នេះ សូម្បីតែមួយ គឺងាយស្លាប់ដល់ទៅ ៨៥% នៅអំឡុងពេលនៃការសិក្សាដែលមានរយៈពេល ២០ឆ្នាំ នៅ ខណៈដែលការកើនឡើងនូវការប្រឈមមុខ គឺមាន ៣៤៥% សម្រាប់អ្នកដែលមានទម្លាប់អាក្រក់ទាំងនេះចំនួន ៤។

យើងបង្កឲ្យមានការខូចខាតជាច្រើនចំពោះបេះដូង ដោយប្រព្រឹត្តនូវទម្លាប់អាក្រក់ចង្រៃៗ ដែលអាចនឹងមានគ្រោះថ្នាក់ខ្ពស់បំផុតសម្រាប់ខ្លួនឯងផ្ទាល់ មានដូចជា ការបរិភោគអាហារមិនល្អ របៀបរបបរស់នៅទំនេរពេក ការជក់បារី បរិភោគជាតិអំបិលច្រើន ពិសារគ្រឿងស្រវឹងច្រើន ព្រមទាំងលើសទម្ងន់ និងជំងឺធាត់។

ទីមួយ ការបរិភោគចំណីអាហារមិនល្អ។ នំបុ័ងឆ្អិនឧស្សាហកម្ម សាច់ក្រក ជំឡូងបារាំងចៀន និងក្រែម ដែលមានផ្ទុកនូវបរិមាណដ៏ច្រើននៃខ្លាញ់កែច្នៃ អំបិល និងស្ករ ទាំងនេះមិនគ្រាន់តែអាចប៉ះពាល់ដល់បេះដូងប៉ុណ្ណោះទេ។ ប៉ុន្តែពួកវាក៏បន្ថែមគីឡូឲ្យរាងកាយផងដែរ។ យើងគួរជំនួសពួកវាដោយបន្លែ និងផ្លែឈើ និងគ្រាប់ធញ្ញជាតិ ខ្លាញ់មិនឆ្អែត ប្រូតេអ៊ីនល្អ ដែលមានប្រភពពីសណ្តែក សាច់ដុង ត្រី និងពពួកបក្សី ព្រមទាំងពពួកស្មៅ ហើយ និងគ្រឿងទេស។ យើងគួរលុបបំបាត់ផងដែរ នូវចំណីអាហារកែច្នៃ និងនំប៉័ងស អង្ករសម្រិតពេក ជំឡូងបារាំងចៀន សាច់ក្រហម និងភេសជ្ជៈមានជាតិហ្គាស ឬភេសជ្ជៈមានជាតិស្ករដទៃៗ ទៀត។

ទី២ មានរបៀបរបបរស់នៅទំនេរពេក។ ប្រសិនបើការងាររបស់យើងទាមទារឲ្យយើងនៅអង្គុយពេញមួយថ្ងៃ ចូរដើរ ៥នាទី នៅរៀងរាល់ម៉ោង។ កាយវិការដ៏តិចតួចនេះអាចថែរក្សាសសៃឈាមអាកទែររបស់យើងឲ្យមានភាពបត់បែន និងធានាឲ្យយើងមានចរាចរណ៍ដ៏ល្អនៃឈាម។ នេះបើយោងតាមការសិក្សាមួយនៃសកលវិទ្យាល័យអ៊ីនឌីយ៉ាណា នៅសហរដ្ឋអាមេរិក នៅខែសីហា ឆ្នាំ២០១៤ និងដែលចុះផ្សាយនៅក្នុងព្រឹត្តិបត្រវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រ។

មនុស្សដែលមាននិន្ទ្រាការអង្គុយ ៥ម៉ោង និងច្រើនជាងនេះ នៅក្នុងមួយថ្ងៃ មានការប្រឈមមុខនឹងជំងឺខ្សោយបេះដូងពីរដងច្រើនជាងអ្នកដែលសកម្ម។ នេះបើយោងតាមការសិក្សាមួយដែលផ្សព្វផ្សាយកាលពីខែមករា ឆ្នាំ២០១៤ នៅក្នុងសារព័ត៌មាននៃសមាគមបេះដូងអាម៉េកាំង។

ទី៣ ការជក់បារី។ យោងតាមសមាគមបេះដូងជាតិ នៅវិទ្យាស្ថានបេះ សួត និងឈាម នៅសហរដ្ឋអាមេរិក បានឲ្យដឹងថា សារធាតុគីមីដែលមាននៅក្នុងផ្សែងបារីបំផ្លាញដល់កោសិកាឈាម។ មុខងាររបស់បេះដូងក៏អាចត្រូវបានបំផ្លាញ បំផ្លាញទាំងរចនាសម្ព័ន្ធ និងមុខងាររបស់សរសៃឈាម។ ការខូចខាតទាំងនេះ បង្កើនហានិភ័យនៃការឡើងរឹងនៃសរសៃឈាមអាកទែរ។ ការឡើងរឹងនៃសរសៃឈាមអាកទែរគឺជាជំងឺមួយដែលនៅក្នុងនោះសារធាតុដែលមានលក្ខណៈជាបន្ទះៗ ត្រូវបានបង្កើតឡើងនៅក្នុងសរសៃអាកទែរ។ ឆ្លងកាត់តាមពេលវេលា បន្ទះទាំងនេះរឹងឡើងៗ នឹងធ្វើឲ្យសរសៃឈាមឡើងរួញ ដែលទាំងនេះកម្រិតឲ្យមានលំហូរឈាម ទៅកាន់សរីរាង្គ និងផ្នែកដទៃទៀតនៃរាងកាយ។ ប្រសិនបើបន្ទះទាំងនេះគរផ្តុំនៅក្នុងសរសៃឈាមអាកទែរបេះដូង ជំងឺសរសៃឈាមបេះដូងក៏កើតមានឡើង។ ជំងឺសរសៃឈាមបេះដូងនេះអាចបង្កបានជាការឈឺចាប់នៅក្នុងទ្រូង ការគាំងបេះដូង ការខ្សោយបេះដូង ចង្វាក់បេះដូងមិនទៀងទាត់ ឬក៏សេចក្តីស្លាប់ផងដែរ។

ការញៀនបារី គឺជាកត្តាមួយនៃការប្រឈមមុខដ៏សំខាន់នៃជំងឺបេះដូង ជាពិសេសនៅពេលដែលវាពាក់ព័ន្ធនឹងកត្តាប្រឈមមុខដទៃទៀត ដូចជា អត្រាដ៏ខ្ពស់នៃកូឡេស្តេរ៉ុលនៅក្នុងឈាម សំពាធសរសៃឈាមដ៏ខ្ពស់ ការលើសទម្ងន់ និងភាពធាត់។

ទី៤ ការបរិភោគអំបិលច្រើន។ ការបរិភោគសារធាតុសូដ្យូមច្រើនពេកអាចធ្វើឲ្យកើតរោគទាស់នោម និងការឡើងសំពាធសរសៃឈាមអាកទែរ។ ទោះបីជាយើងមិនបានដាក់ចំណីអាហារច្រើននៅក្នុងម្ហូបអាហាររបស់យើងក៏ដោយ យើងក៏អាចស្រូបយកសារជាតុអំបិលច្រើនពេកផងដែរ។ វិទ្យាស្ថានបេះដូង សួត និងឈាមអាម៉េរិកាំង បានរាយការណ៍ថា អាហារកែច្នៃ រួមមាន បន្លែកំប៉ុង ទឹកស៊ុប សាច់ត្រជាក់ អាហារពេលល្ងាចបង្កក និងអាហារសម្រន់ប្រៃដទៃទៀតៗ មានផ្ទុកនូវសារធាតុអំបិលជាច្រើន។

ទី៥ ការលើសទម្ងន់ ឬធាត់។ ការលើសឈាមមានទំនាក់ទំនងនឹងការលើសទម្ងន់ និងភាពធាត់តាមរបៀបជាច្រើន។ លើសទម្ងន់ ឬធាត់ជ្រុល អាច បង្កឲ្យមានសំពាធសរសៃឈាមអាកទែរ ដោយសារតែបេះដូងរបស់យើងត្រូវការសប់ឈាមកាន់តែខ្លាំងដើម្បីផ្គត់ឈាមឲ្យបានទៅគ្រប់កោសិការ។ ការលើសជាតិខ្លាញ់ក៏អាចបង្កឲ្យខូចខាតតម្រងនោម ដែលតាមធម្មតាជាអ្នកជួយតម្រែតម្រង់សំពាធឈាម។

ទី៦ ការបរិភោគគ្រឿងស្រវឹងច្រើន។ យោងតាមសមាគមសុខភាពអាម៉េកាំង ការពិសារគ្រឿងស្រវឹងច្រើនពេក អាចបង្កើនកម្រិតនៃជាតិខ្លាញ់ខ្លះនៅក្នុងឈាមដូចជាខ្លាញ់ទ្រីគ្លីសេរីត។ គ្រឿងស្រវឹងក៏អាចបង្កឲ្យសំពាធសរសៃឈាមអាកទែរ ការខ្សោយបេះដូង និងការកើនឡើងនៃការស្រូបយកកាឡូរី។ ការពិសាលើសលុបនៃគ្រឿងស្រវឹងអាចបង្កគ្រោះថ្នាក់ដល់សរសៃឈាមខួរក្បាល ព្រមទាំងបញ្ហាបេះដូងធ្ងន់ធ្ងរដទៃៗទៀត។

ជាចុងក្រោយ ជំងឺបេះដូងគឺជាបញ្ហាដែលយើងមិនគួរមើលរំលង ប្រសិនបើមានការសង្ស័យ ណាមួយទាក់ទងទៅនឹងបញ្ហាបេះដូង សូមយើងទៅពិគ្រោះយោបល់ជាមួយគ្រូពេទ្យជំនាញជាបន្ទាន់។

ដោយ ផាត សំភី

# ក្រសួងទេសចរណ៍ប្រកាសបន្តយុទ្ធនាបង្គន់ស្អាតនិងភោជនីយដ្ឋានគ្មានសំរាមក្រោមតុ

លោកថោងខុនរដ្ឋមន្ត្រីក្រសួងទេសចរណ៍បានប្រកាសកាលពីពេលថ្មីៗនេះឲ្យបន្តអនុវត្តយុទ្ធនាការអនាម័យបង្គន់សាធារណៈ និងភោជនីយដ្ឋាន-អាហារដ្ឋានគ្មានសំរាមក្រោមតុនៅទូទាំងប្រទេស។

លោក ថោង ខុន បានប្រកាសឱ្យថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធក្រោមឱវាទក្រសួងទាំងអស់ ត្រូវបន្តសហការរួមគ្នាជាមួយផ្នែកឯកជន ផ្នែកពាក់ព័ន្ធនានាអនុវត្ត "យុទ្ធនាការអនាម័យបង្គន់សាធារណៈ និងភោជនីយដ្ឋាន-អាហារដ្ឋានគ្មានសំរាមក្រោមតុនៅទូទាំងប្រទេស" បន្តចាប់ពីចុងឆ្នាំ២០១៨ ដល់ពេញមួយឆ្នាំ២០១៩ ដាច់ខាតត្រូវធ្វើឱ្យមានប្រសិទ្ធភាពបំផុត ដើម្បីពង្រឹកការលើកកម្ពស់វិស័យទេសចរណ៍កម្ពុជា ឱ្យមានភាពល្អប្រសើរមួយកម្រិតទៀតនោះ។

ការណែនាំអនុសាសន៍យ៉ាងដូច្នេះ ត្រូវបានលើកឡើងក្នុងកិច្ចប្រជុំបូកសរុបការងារក្នុងឆមាសទី៣ នៃឆ្នាំ២០១៨ និងលើកទិសដៅអនុវត្តបន្តនៅឆមាសទី៤ នៃឆ្នាំ២០១៨ និងឆ្នាំបន្តបន្ទាប់ ដែលកិច្ចប្រជុំនេះបានធ្វើឡើងនាថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ នៅទីស្តីការក្រសួងទេសចរណ៍។

ក្នុងឱកាសនោះ លោក រដ្ឋមន្ត្រីបានណែនាំថា "ត្រូវធ្វើឲ្យបង្គន់អនាម័យទាំងសាធារណៈ ទាំងនៅគ្រប់ភោជនីយដ្ឋានសណ្ឋាគារ និងគ្រប់ទីកន្លែង នៅទូទាំងប្រទេសត្រូវមានអនាម័យស្អាត មានទឹកសាប៊ូ កន្សែងក្រដាស មានអ្នកសម្អាតប្រចាំការទៅតាមស្តង់ដាអាស៊ាន និងអន្តរជាតិ"។

លោករដ្ឋមន្ត្រីបានបន្តទៀតថា គ្រប់ភោជនីយដ្ឋាន អាហាដ្ឋាន និងអាជីវកម្មទេសចរណ៍ទាំងអស់ ត្រូវតែបន្តយកចិត្តទុកដាក់ចំពោះបញ្ហាគុណភាពសេវាកម្ម ម្ហូបអាហារត្រូវមានអនាម័យល្អ តម្លៃសមរម្យពិសេសកុំឱ្យមានសំរាមក្រោមតុជាដាច់ខាត ឬអាចជំនួសដោយកន្សែងត្រដាក់វិញ ក៏ជាការប្រសើរដែរ។

មួយទៀតសោត លោករដ្ឋមន្ត្រីក៏បានបន្តដាស់តឿន និងណែនាំបន្ថែមដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ ដែលចំណុះក្រោមក្រសួងទេសចរណ៍ត្រូវបន្តអនុវត្តការងារតាមតួនាទីរៀងៗខ្លួន ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងផ្នែកជកជន ដើម្បីសម្រេចផែនការយុទ្ធសាស្ត្រការងារទេសចរណ៍ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល សំដៅធ្វើយ៉ាងណាឱ្យវិស័យទេសចរណ៍កម្ពុជា មានការអភិវឌ្ឍឈានឡើងប្រកបដោយគុណភាព ភាពទាក់ទាញ និងផ្តល់ភាពកក់ក្តៅដល់ភ្ញៀវទេសចរ។

ក្នុងរយៈពេល៧ខែ ឆ្នាំ២០១៨ ភ្ញៀវទេសចរអន្តរជាតិដែលមកទស្សនាកម្ពុជាមានចំនួន ៣,៤៥៥,៧១៦នាក់ កើនឡើង ១១.១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៧ ក្នុងនោះពួកគេបានទៅទស្សនាតំបន់អាទិភាពនានារបស់កម្ពុជា រួមមានសៀមរាបអង្គរ ទទួលបានទេសចរអន្តរជាតិ ១,៥៤២,៨៣៩នាក់ កើនឡើង ៩%។ តំបន់ភ្នំពេញ ទទួលបានទេសចរអន្តរជាតិ ១,៩១២,៨៦៧នាក់ កើនឡើង ១៣%។ តំបន់ឆ្នេរសមុទ្រ ទទួលបានទេសចរអន្តរជាតិ ៥៨៩,៤១៣នាក់ កើនឡើង ៣៤.៥%។ តំបន់អេកូទេសចរណ៍ភូមិភាគឦសាន្ត ទទួលបានទេសចរអន្តរជាតិ ៤៧,៩៤១នាក់ កើនឡើង ១០.៦%។

រីឯទេសចរកម្ពុជាដែលចេញទៅក្រៅប្រទេស រយៈពេល៧ខែ ឆ្នាំ២០១៨នេះ មានចំនួន ១,១០៥,០០០នាក់ កើនឡើង ១០.៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៧។

នាឆ្នាំ២០១៨ កម្ពុជាគ្រោងនឹងទទួលទេសចរអន្តរជាតិប្រមាណ ៦.២លាននាក់។ ខណៈដែលក្រសួងបានព្យាករណ៍ថាឆ្នាំ២០២០ កម្ពុជាគ្រោងនឹងទទួលទេសចរអន្តរជាតិ ៧លាននាក់ និងចំណូលទេសចរណ៍ប្រមាណ ៥ពាន់លានដុល្លារអាមេរិក ហើយសង្ឃឹមថា វិស័យនេះនឹងបង្កើតការងារ និងមុខរបរដោយផ្ទាល់ប្រមាណជិត ១លាននាក់។ រហូតដល់ ឆ្នាំ២០២៥ កម្ពុជាគ្រោងនឹងទទួលទេសចរអន្តរជាតិ ១០លាននាក់។ រីឯដល់ ឆ្នាំ២០៣០ កម្ពុជាគ្រោងនឹងទទួលទេសចរអន្តរជាតិ ១៤លាននាក់។

ចំណែកឯកម្មវិធីការងារជាអាទិភាពវិញ គឺត្រូវផ្តោតលើមុំចំនួន៤ រួមមាន មុំទី១៖ ការអភិវឌ្ឍផលិតផលទេសចរណ៍ប្រកបដោយភាពទាក់ទាញ និងភាពច្នៃប្រឌិត។ មុំទី២៖ ការពង្រឹងគុណភាពឧស្សាហកម្មទេសចរណ៍ តាមរយៈការដាក់ចេញ និងការអនុវត្តស្តង់ដាបៃតងសម្រាប់ផលិតផល និងសេវាទេសចរណ៍ "សេវាមួយ ស្តង់ដាមួយ" ទាំងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់តំបន់អាស៊ាន ការពង្រឹងធនធានមនុស្សក្នុងវិស័យទេសចរណ៍ "បុគ្គលិកម្នាក់ ជំនាញមួយ" ពិសេសការបណ្តុះបណ្តាលអ្នកជំនាញវិជ្ជាជីវៈទេសចរណ៍ស្របតាមស្តង់ដាអាស៊ាន និងការគ្រប់គ្រងតាមប្រព័ន្ធ Online។ មុំទី៣៖ ការពង្រឹងការផ្សព្វផ្សាយទេសចរណ៍តាមគ្រប់មធ្យោបាយ។ មុំទី៤៖ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងវិស័យទេសចរណ៍ ( Smart Tourism )។

ក្រៅពីនេះ គម្រោងថ្មីៗដែលក្រសួងទេសចរណ៍កំពុងតែលើកទឹកចិត្តដើម្បីបម្រើដល់វិស័យទេសចរណ៍នោះ គឺរួមមានទីក្រុងទេសចរណ៍វៃឆ្លាត, គោលដៅទេសចរណ៍វៃឆ្លាត ស្អាតនិង បៃតង, តំបន់ទសេចរណ៍ដ៏ទាក់ទាញនៅតំបន់ឆ្នេរ-កោះ មជ្ឈមណ្ឌលវិស្សមកាល និងកីឡាទេសចរណ៍, តំបន់ទេសចរណ៍ផ្ទះទី២, ទេសចរណ៍វៃចំណាស់, ទេសចរណ៍សុខភាព, សួនកម្សាន្តរបស់កុមារនៅតំបន់ទេសចរណ៍, ទេសចរណ៍សត្វព្រៃ, សណ្ឋាគារប្រណីតៗលំដាប់ផ្កាយ៤ និងផ្កាយ៥ ហាងលក់ទំនិញទំនើបៗ ភោជនីយដ្ឋានលំដាប់ខ្ពស់ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ កំពង់ផែទេសចរណ៍ និងអាកាសយានដ្ឋាន) នៅតំបន់គោលដៅទេសចរណ៍មួយចំនួន។

រហូតដល់ឆ្នាំ២០៣០ កម្ពុជាតម្រូវឱ្យមានបន្ទប់សណ្ឋាគារ ១០ម៉ឺនបន្ទប់ ក្នុងនោះបន្ទប់សណ្ឋាគារលំដាប់ផ្កាយ៤ និងផ្កាយ៥ ប្រមាណ៦០% ខណៈបច្ចុប្បន្ននៅទូទាំងប្រទេសកម្ពុជាមានបន្ទប់សណ្ឋាគារប្រមាណ ៤ម៉ឺន៥ពាន់បន្ទប់រួចហើយ ក្នុងនោះបន្ទប់សណ្ឋាគារផ្កាយ៤ និងផ្កាយ៥ មានតែ ២ម៉ឺន៥ពាន់បន្ទប់ប៉ុណ្ណោះ៕


ថតដោយ: លីហៀង

ដោយ អរិយបុត្រ

# យុវនិស្សិតមួយក្រុមចងក្រងគ្នាបង្កើតមុខរបរជួយដល់វិស័យកសិកម្ម




ថតដោយ: សុផានិត

យុវនិស្សិតជាស្ត្រីមួយក្រុម បានចងក្រងគ្នាបង្កើតជាផ្សារសហគមន៍ខ្មែរ ដើម្បីផ្តល់ទីផ្សារសម្រាប់កសិកផលិតកសិផលធម្មជាតិ ដើម្បីជួយខ្លួនឯងផង និងជួយកសិករក៏ដូចជា ប្រជាពលរដ្ឋដែលត្រូវការ ផលិតផលសរីរាង្គសម្រាប់ការហូបចុកផង។

ផ្សារសហគមន៍ខ្មែរ ត្រូវបានបង្កើតឡើងកាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៥ ដោយកញ្ញា ស៊ាយ សុម៉ាលី ជាអ្នកផ្តួចផ្តើម និងមានការចូលរួមពីយុវនិស្សិតជាស្ត្រីភាគច្រើន ដើម្បីជួយរកទីផ្សារសម្រាប់កសិផលរបស់កសិករខ្មែរ ដែលមិនប្រើប្រាស់ជីគីមី និងផ្តល់ជាទីជម្រកសម្រាប់និស្សិតស្ត្រីក្រីក្រដែលមកបន្តការសិក្សានៅរាជធានីភ្នំពេញ។

កញ្ញា ស៊ាយ សុម៉ាលី បានឲ្យដឹងថា ដោយមើលឃើញការលំបាករបស់យុវតីខ្មែរ ដែលចាកចេញពីស្រុកកំណើតមកបន្តការសិក្សានៅភ្នំពេញ ក៏ដូចជាហានិភ័យពីការប្រើប្រាស់ជីគីមីទៅលើដំណាំ និងផលលំបាករបស់កសិករខ្មែរ ដែលដាំដំណាំដោយមិនប្រើជីគីមី លំបាករកទីផ្សារ កញ្ញាបានស្វែងរកយុវនិស្សិតស្ត្រី ដែលក្រីក្រមកសិក្សានៅភ្នំពេញ ដើម្បីចងក្រងគ្នាបង្កើតជាផ្សារសហគមន៍ខ្មែរនេះឡើង។

កញ្ញា បានបញ្ជាក់ថា "យើងបង្កើតជាហាងតូចមួយ ហើយយើងមានបន្ទប់ច្រើនដែលយើងបានជួលផ្ទះមួយល្វែងសម្រាប់លក់ ក៏ប៉ុន្តែនៅខាងលើៗគឺមានកន្លែងស្នាក់នៅសម្រាប់និស្សិតដែលគាត់មកពីបណ្តាខេត្ត ហើយនិស្សិតទាំងអស់នោះជានិស្សិតស្ត្រី។ ព្រោះយើងយល់ឃើញថា ស្ត្រីគាត់ប្រឈមនឹងបញ្ហាច្រើនពេលដែលគាត់មករៀននៅភ្នំពេញ ទី១ គាត់ក្រីក្រគាត់មិនមានលទ្ធភាពជួលបន្ទប់សម្រាប់ស្នាក់នៅ ទី២ គាត់មកសិក្សានៅទីក្រុងភ្នំពេញឪពុកម្តាយមានសេចក្តីព្រួយបារម្ភ ដូច្នេះអ្នកដែលមកសិក្សានៅភ្នំពេញ អ្នកដែលគាត់ចូលរួមជាមួយក្រុមចងក្រងសហគមន៍នោះគាត់អាច មករស់នៅក្នុងហាងផ្សារសហគមន៍ ហើយគាត់ផ្លាស់ប្តូរគ្នាក្នុងការសិក្សា"។

ផ្សារសហគមន៍ខ្មែរ មុនពេលទទួលយកបន្លែ ផ្លែឈើ ត្រី សាច់ ពីកសិករ គឺត្រូវចុះទៅដោយផ្ទាល់ដើម្បីសិក្សាពីបច្ចេកទេសដាំដុះ និងធ្វើកំណត់សម្គាល់ឲ្យច្បាស់ថាតើកសិករ ពិតជាមិនបានប្រើប្រាស់ជីគីមីពិតប្រាកដមែន ឬយ៉ាងណា ទើបផ្សារសហគមន៍ខ្មែរនេះ ផ្តល់ទីផ្សារសម្រាប់លក់ជូនកសិករ។ បន្លែ ត្រី សាច់ ធម្មជាតិរបស់កសិករខ្មែរ ភាគច្រើននាំយកពីខេត្តជាង ១០ មាននៅ ខេត្ត តាកែវ កំពង់ស្ពឺ សៀមរាប បាត់ដំបង ប៉ៃលិន កោះកុង កំពត បន្ទាយមានជ័យ ឧត្តរមានជ័យ រតនគិរី និងខេត្តផ្សេងៗមួយចំនួនទៀត។

កញ្ញា ឃិន ធារី ជានិស្សិតកំពុងបន្តការសិក្សា និងជាសមាជិកម្នាក់របស់ផ្សារសគមន៍ខ្មែរ បានប្រាប់ឲ្យដឹងថា កញ្ញាសប្បាយចិត្តដែលបានចូលរួមចងក្រងជាផ្សារសហគមន៍នេះឡើង។ កញ្ញាបន្តថា ផ្សារសហគមន៍នេះកើតឡើងពីទឹកចិត្តនិស្សិតស្ត្រី ដែលចង់ជួយស្ត្រី ឲ្យបានបន្តការសិក្សាខ្ពស់ដូចកូនប្រុស និងជាពិសេសជួយប្រជាកសិករខ្មែរឲ្យមានទីផ្សារលក់កសិផលធម្មជាតិ ដោយមិនចំបាច់ធ្វើចំណាកស្រុកទៅក្រៅប្រទេស។

កញ្ញា ឃិន ធារី បានបញ្ជាក់ថា "ពួកយើងសុទ្ធតែអ្នកនៅខេត្តផ្សេងៗគ្នា ហើយអត់ដែលស្គាល់គ្នាទៀត ប៉ុន្តែពួកយើងអាចបានស្គាល់គ្នារស់នៅក្នុងផ្សារហ្នឹង ហើយយើងបានជួយដល់សហគមន៍ ហើយជួយដល់ខ្លួនយើង ហើយជួយដល់ក្រុមនិស្សិតដែលក្រីក្រ ដូចជាពួកគាត់យើងអាចឲ្យគាត់បានស្នាក់នៅយើងអាចឲ្យគាត់បានរៀន បើសិនជាពួកគាត់ជួយការងារយើងច្រើន យើងមានប្រាក់ឧបត្ថមឲ្យគាត់តិចតួចដើម្បីឲ្យពួកគាត់អាចមានលទ្ធភាពទៅរៀនទៀត ព្រោះធម្មតាពួកគាត់ដែលមករៀននេះ គឺក្រីក្រគាត់អត់មានលទ្ធភាពទេ"។

ចំណែកកញ្ញា ហឿក សុខួន សមាជិករបស់ផ្សារសហគមន៍ខ្មែរមួយរូបទៀត បានឲ្យដឹងថា កញ្ញាមានស្រុកកំណើតនៅខេត្តឧត្តរមានជ័យ បានមកបន្តការសិក្សានៅរាជធានីភ្នំពេញ និងបានចូលរួមក្នុងផ្សារសហគមន៍ខ្មែរនេះ បានរយៈមួយឆ្នាំហើយ។ កញ្ញាប្រាប់ថា ជីវភាពគ្រួសារកញ្ញាក្រីក្រដែលមានបងប្អូនចំនួន ៧នាក់ ហើយបានចូលរៀនត្រឹមតែពីរនាក់ប៉ុណ្ណោះ គឺរូបកញ្ញា និងប្អូនប្រុសរបស់កញ្ញាម្នាក់។ កញ្ញាបន្តថា ការចូលរួមក្នុងផ្សារសហគមន៍នេះ បានជួយដល់នាងឲ្យទទួលបានកន្លែងស្នាក់នៅ នឹងអាចបន្តការសិក្សាបានដោយមិនព្រួយបារម្ភពីសុវត្ថភាព។

កញ្ញា ហឿក សុខួនបានបញ្ជាក់ថា "ការស្នាក់នៅគឺពិបាក ហើយយើងគឺត្រូវចំណាយលើទឹកភ្លើង ផ្ទះ គ្រប់យ៉ាង អាហារហូបចុកតែបើនៅទីហ្នឹង និយាយរួមទៅគឺផ្សារសហគមន៍ជួយខ្ញុំបានច្រើន និយាយទៅផ្ទះក៏មិនពិបាកអស់ ថ្លៃចាយវាយម្ហូបអាហារ ក៏មិនពិបាកអស់ ព្រោះអីនៅហ្នឹងគាត់ជួយខ្ញុំគ្រប់យ៉ាង និយាយរួមទៅ នៅផ្សារសហគមន៍គាត់ជួយនិស្សិតស្ត្រីក្រីក្រអញ្ចឹង"។

អតិថិជនម្នាក់របស់ផ្សារសហគមន៍ខ្មែរ លោក អ៊ិន ដារារុធ ដែលសព្វថ្ងៃជាគ្រូបង្រៀនមួយរូបមានប្រសាសន៍ថា គាត់មានក្តីបារម្ភជាខ្លាំងពីសុវត្ថិភាពចំណីអាហារសម្រាប់ខ្លួនលោកផ្ទាល់ ក៏ដូចជាកូនៗរបស់លោក ដោយសារតែលោកមើលឃើញថា នៅលើទីផ្សារមានបន្លែ ត្រី សាច់ ជាច្រើនដែលនាំចូលពីបរទេស។ លោក បន្តថា ការបរិភោគបន្លែធម្មជាតិ គឺមានអត្ថប្រយោជន៍ណាស់សម្រាប់សុខភាព ព្រោះបន្លែធម្មជាតិអាចប្រឆាំងនឹងជំងឺផ្សេងៗ ក៏ប៉ុន្តែបើបន្លែនោះមានសារធាតុគីមី វានឹងធ្វើមនុស្សម្នាក់ងាយនឹងកើតជំងឺដែលពិបាកព្យាបាល ហើយក៏អាចកើតជំងឺដែលមិនអាចព្យាបាលបានផងដែរ។

លោក អ៊ិន ដារារុធ ៖ "ធម្មតាបន្លែគឺអាចប្រឆាំងនឹងជំងឺផ្សេងៗទៀតបាន បើសិនយើងបរិភោគបន្លែត្រូវ តែបើយើងហូបបន្លែខុសវិញ គឺនឹងធ្វើឲ្យយើងមានជំងឺមហារីក មានមេរោគអី រោគអីផ្សេងៗធ្វើឲ្យសុខភាពយើងកាន់តែទន់ខ្សោយទៅៗ បាទការហូបបន្លែត្រឹមត្រូវ បន្លែធម្មជាតិនេះ វាល្អណាស់សម្រាប់សុខភាពយើងអញ្ចឹងសុំឲ្យបងប្អូនទាំងអស់ជួយគាំទ្របន្លែធម្មជាតិយើង"។

ដោយ សុផានិត

# កម្មករក្នុងវិស័យឧស្សាហកម្មកាត់ដេរនៅតែទទួលបានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលនៅក្នុងអណត្តិទី៦ក្រោមការដឹកនាំដោយ សម្តេចតេជោ ហ៊ុន សែន នៅតែបន្តការយកចិត្តទុកដាក់ លើកម្មករ និងកម្មការិនីនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ និងវាយនភណ្ឌ។

កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ក្រោយពេលដែលរាជរដ្ឋាភិបាលអណត្តិទី៦ ត្រូវបានបង្កើតជាផ្លូវការ និងបញ្ចប់ដំណើរបេសកម្មនៅក្រៅប្រទេស សម្តេចតេជោ ហ៊ុន សែន បានអញ្ជើញជួបសំណេះសំណាលជាមួយកម្មករ កម្មការិនីប្រមាណ ២៧,៤៤៤នាក់ មកពីរោងចក្រ សហគ្រាស ចំនួន២៤ ដែលកិច្ចសំណេះសំណាលនេះបានធ្វើឡើងនៅភូមិស្វាយទាប ឃុំអង្គពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

ម្តេចតេជោនាយករដ្ឋមន្ត្រីបានអះអាងថានឹងបន្តកិច្ចការដែលត្រូវជួបជាមួយនឹងកម្មករ/ការិនី ឲ្យអស់ហើយ បន្ទាប់ពីការជួបអស់ហើយសម្តេចនិងជួបវិលជុំ ហើយនេះជាដំណើរនៃការអនុវត្តនូវគោលនយោបាយឧស្សាហកម្ម ២០១៥-២០២៥ ជាមួយនឹងការចូលរួមចំណែក និងការដោះស្រាយបញ្ហាកង្វល់នានា ឬក៏បញ្ហាប្រឈមនានាដែលនៅសេសសល់ជំរុញដំណើរទៅមុខទាំងអស់គ្នាលើការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមសម្រាប់ប្រទេសកម្ពុជា។

សូមបញ្ជាក់ថាសម្តេចតេជោ ហ៊ុន សែន បានចាប់ផ្តើមចុះជួបសំណេះសំណាលជាមួយកម្មករ កម្មការិនីមកពីតាមរោងចក្រសហគ្រាស និងគ្រឹះស្ថាននានាតាំងពីថ្ងៃអាទិត្យ ទី២០ ខែសីហា ឆ្នាំ២០១៧ មកម្ល៉េះ។ ជំនួបសំណេះសំណាលរវាងសម្តេចតេជោហ៊ុនសែន និងកម្មករ កម្មការិនីមានចំនួន ៥៥ លើកមកហើយ។ ជំនួប ៥៥ លើកនេះ មានកម្មករ និងកម្មការិនីសរុប ៧៦៦.៣៣៩នាក់។

តាមរយៈដំណើរចុះជួបនឹងសំណេះសំណាលជាបន្តបន្ទាប់នោះសម្តេចតេជោ ហ៊ុន សែន បានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់កម្មករកម្មការិនី ហើយក៏ធ្វើឲ្យមានសុខដុមនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ សម្លៀកបំពាក់ និងស្បែកជើង។

យោងតាមឯកសារមួយរបស់គណរដ្ឋមន្ត្រីបានបង្ហាញ ពីពេលនេះ រហូតដល់ខែកុម្ភៈ ឆ្នាំក្រោយ សម្តេចតេជោ ហ៊ុន សែន មានកម្មវិធីជាមួយនឹងកម្មករ និងកម្មការិនីរោងចក្រកាត់ដេរចំនួនយ៉ាងហោចណាស់ ៩ទៀត នៅកន្លែងផ្សេងៗគ្នា ដូចជានៅខេត្តកណ្តាល តាកែវ កំពង់ស្ពឺ កំពត កោះកុងជាដើម។

បើតាមការអះអាងរបស់ក្រសួងការងារ វិស័យការងារនៅកម្ពុជា បន្តអភិវឌ្ឍរីកចម្រើន ក្នុងអត្រាមានការងារធ្វើ៩៩,៣% ជាមួយនឹងបរិមាណការងារសរុបមានប្រមាណជិត ១០លាននាក់។ សហគ្រាសគ្រឹះស្ថានសេដ្ឋកិច្ចក្នុងប្រព័ន្ធដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួនសរុបជាង ១២.០០០ គ្រឹះស្ថាន សហគ្រាសគ្រឹះស្ថានសេដ្ឋកិច្ចក្រៅប្រព័ន្ធសរុបមានចំនួនជិត ៦សែន មានកម្មករចំនួនជាង ២,៤លាននាក់, វិស័យកសិកម្មប្រមាណជាង៤លាននាក់, ពលករធ្វើការនៅក្រៅប្រទេសមានចំនួនប្រមាណ១,២លាននាក់ និងមន្ត្រីសា-ធារណៈចំនួនប្រមាណជាង ៥សែននាក់។

បច្ចុប្បន្នរាជធានីភ្នំពេញមានរោងចក្រសហគ្រាសគ្រឹះស្ថានសរុបចំនួន ៤.៤៥៣ មានកម្មករ និយោជិតចំនួន ៧៧២.៨៣៦ នាក់ ដែលមានប្រាក់ឈ្នួលសរុបជាង ១.៨៥៥លានដុល្លារក្នុងមួយឆ្នាំ។ ក្នុងនោះរោងចក្រកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើងមានចំនួន ៦៨៨ មានកម្មករនិយោជិតចំនួន ៤០៨.២៣៤នាក់ ដែលមានប្រាក់ឈ្នួលសរុបជាង ៩៧៩ លានដុល្លារក្នុងមួយឆ្នាំ។

កម្មការិនី នាង ចិន្តា ដែលជាកម្មការិនីមកពីរោងចក្រមួយនៅក្នុងចំណោមរោងចក្រទាំង២៤ ដែលសម្តេចតេជោ បានអញ្ជើញចុះទៅសាកសួរសុខទុក្ខកាលពីថ្ងៃទី១៩ ខែកញ្ញានោះ បានបង្ហាញនូវក្តីរំពឹងថា នាងនឹងទទួលបានប្រាក់ខែបន្ថែមទៀត។

ចិន្តា អះអាងថា តាមប្រសាសន៍របស់សម្តេចតេជោ ខ្ញុំសង្ឃឹមថា ប្រាក់ខែគោលខ្ញុំនឹងបានច្រើនជាង ឥឡូវនៅឆ្នាំ ក្រោយ។

កញ្ញា បានបន្តថា វាពិតជារីករាយនៅពេលដែលសម្តេចតេជោ ហ៊ុន សែន និយាយរឿងប្រាក់ខែបែបនេះ ហើយបន្តយកចិត្តទុកដាក់នឹងសុខទុក្ខរបស់ពួកយើង។

កញ្ញាបានបញ្ជាក់ថា "វាពិតជាអស្ចារ្យដែលយើងជាកម្មករ បានជួប បានថតរូបសែលហ្វី ស្រួលៗជាមួយនឹងនាយករដ្ឋមន្ត្រីបែបនេះ"។

*ដោយ អរិយបុត្រ*



*រូបភាពពីហ្វេសបុក សម្តេចតេជោ ហ៊ុន សែន*

# ពលរដ្ឋយល់ឃើញខុសៗគ្នាចំពោះការបង្កើតឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់



រូបភាពពីហ្វេសប៊ុក សម្តេចតេជោ ហ៊ុន សែន

ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ត្រូវបានព្រះមហាក្សត្រចុះហត្ថលេខាលើព្រះរាជក្រឹត្យរួចរាល់ ហើយកាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ខណៈដែលប្រជាពលរដ្ឋកម្ពុជា បានបញ្ចេញទស្សនៈ និងយោបល់ផ្សេងៗគ្នា ជុំវិញ ការបង្កើតឧត្តមក្រុមប្រឹក្សាមួយនេះឡើង។

ក្រោយពេល ដែលឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់នេះបានបង្កើតឡើង ហើយសមាជិកឧត្តមក្រុមប្រឹក្សានេះទាំងអស់ប្រមាណជា ៣០នាក់ បានទទួលការតែងតាំងឋានៈស្មើនឹងទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ប្រជាពលរដ្ឋមួយចំនួន ក៏គាំទ្រ ខ្លះក៏សម្តែងមតិជំទាស់ ទៅតាមការយល់ឃើញរបស់ពួកគេរៀងៗខ្លួន។

នៅក្នុងចំណោមអ្នកទាំងនោះ អ្នកខ្លះក៏បានសរសេរបញ្ចេញយោបល់តាមបណ្តាញសង្គម ថែមទៀត ផងក្រោយពេលដែលឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់បានបង្កើតឡើង ហើយតំណាង គណបក្សនយោបាយដែលធ្លាក់ឆ្នោតទាំងនោះ បានទទួលការតែងតាំងពី ព្រះមហាក្សត្រ ដោយសារនោះថា "វាគ្មានជាប់សាច់ញាតិអីសោះ ហេតុខ្ញុំត្រូវចិញ្ចឹម ឯកឧត្តម លោកជំទាវ ទាំងខ្លួនខ្ញុំមិនមែនជាឧកញ៉ា" "ស្តាយលុយបង់ពន្ធ" អ្នកខ្លះក៏ថា "ឯកឧត្តម និងលោកជំទាវព្រោងព្រាត ថវិកាជាតិគរបន្ទុកលើពលរដ្ឋ"។ ដោយឡែកអ្នកខ្លះក៏បញ្ចេញនូវគំនិតគាំទ្រ "ការបង្កើត ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់នេះ គឺដើម្បីចូលរួមចំណែក រក្សាសន្តិភាព ការពារថែរក្សាមាតុភូមិកម្ពុជានៃយើង និងបន្តចូលរួមចំណែកការអភិវឌ្ឍប្រទេសកម្ពុជាក្នុងនាមជាកូនខ្មែរ ទាំងអស់គ្នា។ អ្នកខ្លះទៀតក៏ថា "ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ នេះជាការបើកទំព័រប្រវត្តិសាស្ត្រថ្មីមួយ សម្រាប់ប្រជាជាតិកម្ពុជា ក្នុងអាណត្តិទី៦"។ អ្នកខ្លះទៀតក៏ថា "ការបង្កើតឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់នេះជាផ្នែកមួយនៃនយោបាយឈ្នះឈ្នះ ដ៏ថ្មីស្រឡាង និងជាស្មារតីផ្សះផ្សារជាតិមួយថ្មី"។

ទាំងនេះគឺជាគំនិតនឹងទស្សនៈផ្ទាល់ខ្លួនមួយចំនួន ដែលគេបានចែករំលែកនៅលើបណ្តាញសង្គម ប៉ុន្តែដោយឡែក លោក លី សំណាង ដែលជាអាជីវករវ័យ ៤៧ ឆ្នាំមួយរូប បានឲ្យដឹងថា លោកមិនគាំទ្រការបង្កើតឲ្យមានឧត្តមក្រុមប្រឹក្សានេះឡើងទេ ប៉ុន្តែបើថ្នាក់ដឹកនាំសម្រេចចិត្តហើយក៏មិនជាថាអ្វីដែរ។

លោកបានបញ្ជាក់ថា "ជាទស្សនៈខ្ញុំ ចាញ់ហើយចាញ់ទៅ នៅចង់បានងារឯកឧត្តម លោកជំទាវ ស្អីដែរ អស់លោក និងលោកស្រី ប្រធាន និងអគ្គលេខាធិការគណបក្សនយោបាយទាំងនោះ ប៉ុន្តែ ក៏មិនដឹងជាទៅថាម៉េចទេ បើថ្នាក់ដឹកនាំប្រទេស គេត្រូវការអញ្ចឹងហើយនោះ"។

លោក គឹម សុវណ្ណ ដែលជាប្រជាពលរដ្ឋអាយុ ៣៩ឆ្នាំ បានចូលរួមបញ្ចេញទស្សនៈរបស់លោកថា វាពិបាកនិយាយថា គាំទ្រ និងមិនគាំទ្រ។

លោកបានបញ្ជាក់ថា "ពិបាកនិយាយថា គាំទ្រ ឬមិនគាំទ្រ! ខ្ញុំដូចជាវិលវល់ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ បើជ្រុលជាសម្រេចបង្កើតហើយ គួរតែរួមគ្នាធ្វើការឲ្យវាមានប្រយោជន៍ ហើយឯកឧត្តម និងលោកជំទាវទាំងនោះ គួរតែខំធ្វើការ ដើម្បីជាតិទៅ កុំយកតែងារ និងប្រាក់ខែ ដែលរាស្ត្រខំបង់ពន្ធជូនរាល់ពេលនោះ អត់ប្រយោជន៍"។

លោកមេធាវីមួយរូបដែលមិនបញ្ចេញឈ្មោះ បានមានប្រសាសន៍ថា សង្គមយើងហើយ លទ្ធិប្រជាធិបតេយ្យនៅស្រុកយើងវល់តែម្តង។

លោកបានបញ្ជាក់ថា "ឲ្យតែបានបង្កើតគណបក្សនយោបាយ ហើយបានចូលរួមបោះឆ្នោត ទោះចាញ់ក៏មានប្រាក់ខែ មានតួនាទី មានងារ កិត្តិយសដែរហ៎..."។

តាមព្រះរាជក្រឹត្យ គោលដៅនៃការបង្កើតនូវឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់នេះឡើងគឺ នៅក្នុងគោលបំណងលើកស្ទួយរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ដើម្បីប្រមូលធាតុចូលនៃទស្សនៈពហុគំនិតជាប្រយោជន៍ដល់ការស្ថាបនាជាតិ។ ឧត្តមក្រុមប្រឹក្សានេះ ត្រូវបានបង្កើតឡើង ដោយមានការចូលរួមពីគណបក្សនយោបាយទាំងឡាយដែលបានចូលរួមក្នុងការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ នៃរដ្ឋសភា។ ការចូលរួមរបស់គណបក្សនយោបាយ គឺអនុលោម ដោយឈរនៅលើគោលការណ៍ស្ម័គ្រចិត្តរបស់សាមីគណបក្សនីមួយៗ។

រហូតមកដល់ពេលបច្ចុប្បន្ននេះ នៅក្នុងចំណោមគណបក្សទាំង២០ ដែលបានចូលរួមការបោះឆ្នោត កាលពីថ្ងៃទី២៩ កក្កដា ២០១៨ គឺមានតែ ១៦គណបក្សប៉ុណ្ណោះ ដែលបានចូលរួមជាផ្លូវការ។

កិច្ចការរបស់ឧត្តមក្រុមប្រឹក្សានេះ គឺជួបប្រជុំពិគ្រោះ និងផ្លាស់ប្តូរយោបល់រៀងរាល់មួយខែម្តង តាមការកោះប្រជុំពីប្រធានឧត្តមក្រុមប្រឹក្សាដែលអនុវត្តតាមការផ្លាស់ប្តូរមួយខែម្តង។ ឧត្តមក្រុមប្រឹក្សានេះគឺ នឹងជួបពិគ្រោះ និងផ្លាស់ប្តូរយោបល់ជាមួយនឹងនាយករដ្ឋមន្ត្រី រៀងរាល់៦ខែម្តង តាមការកោះប្រជុំរបស់នាយករដ្ឋមន្ត្រី។ ក្នុងករណីចាំបាច់ ក្នុងចន្លោះ ៦ខែ ឧត្តមក្រុមប្រឹក្សានេះ អាចជួបប្រជុំពិគ្រោះ និងផ្លាស់ប្តូរយោបល់ ជាវិសាមញ្ញជាមួយនាយករដ្ឋមន្ត្រីតាមការស្នើសុំពីប្រតិភូគណបក្ស ចំនួន ១/៣យ៉ាងតិច។ ក្នុងករណីមានធុរៈ នាយករដ្ឋមន្ត្រីអាចចាត់តាំងឧបនាយករដ្ឋមន្ត្រីមួយរូប ជាតំណាងដឹកនាំកិច្ចប្រជុំវិសាមញ្ញនេះ។

ដោយ អរិយបុត្រ

# ពិព័រណ៍អាស៊ាន-ចិន គឺជាច្រកពាណិជ្ជកម្មដ៏ចម្បងមួយរវាងចិននិងអាស៊ាន

ពិព័រណ៍អាស៊ាន-ចិន ត្រូវបានគេដឹងថា គឺជាគំនិតផ្តួចផ្តើមមួយរវាងមេដឹកនាំចិន និងអាស៊ានទាំង១០ នៅក្នុងការជំរុញពាណិជ្ជកម្ម ពង្រឹងការវិនិយោគ និងសមាហរណកម្មសេដ្ឋកិច្ចរវាងទីផ្សារដ៏ធំទាំងពីរ។

ពិព័ណ៌អាស៊ាន-ចិន ត្រូវបានគេដឹងថា ត្រូវបានមេដឹកនាំចិនរៀបចំជារៀងរាល់ឆ្នាំ នៅមជ្ឈមណ្ឌលពាណិជ្ជកម្ម និងតាំងពិព័រណ៍មួយ ដែលមានទីតាំងនៅក្នុងទីក្រុងណាន់នីងនៃតំបន់ស្វ័យ ក្វាងស៊ី ឈួន នៃប្រទេសចិន តាំងពីឆ្នាំ២០០៣មករហូតដល់ពេលបច្ចុប្បន្ន។ ការដែរចិនកំណត់យកទីតាំងសម្រាប់រៀបចំនៅទីក្រុងណាន-នីងនេះ គឺដោយសារតែនៅទីនោះ ត្រូវបានគេដឹងថា គឺជាកន្លែងដែលមានភូមិ-សាស្ត្រ ជាប់នឹងអាស៊ានជាពិសេស គឺវៀតណាម និងឈូងសមុទ្រតុងកឹង។

កម្មវិធីនេះ ត្រូវបានរៀបចំក្រោមកិច្ចសហការដោយក្រសួងពាណិជ្ជកម្ម ឬក៏ឧស្សាហកម្មចិន និងសមភាគី អាស៊ានទាំង ១០ ដែលរួមមាន កម្ពុជា វៀតណាម ឡាវ ភូមា ថៃ ប្រុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពិន និងលេខាធិការដ្ឋានអាស៊ាន។

មេដឹកនាំអាស៊ានទាំងអស់គឺតែងតែឲ្យតម្លៃនិងបានចូលរួមកម្មវិធីពិព័រណ៌នេះជាបន្តបន្ទាប់ ប៉ុន្តែនៅក្នុងចំណោមមេដឹកនាំអាស៊ាន សម្តេចតេជោ ហ៊ុន សែន គឺជាមេដឹកនាំអាស៊ានមួយរូប ដែលតែងតែផ្តល់តម្លៃ និងចូលរួមជាបន្តបន្ទាប់ពោល គឺសឹងតែបង្ហាញមុខនៅក្នុង កម្មវិធីនេះជារៀងរាល់ឆ្នាំ ដោយសារតែនេះគឺជាច្រកពាណិជ្ជកម្ម វិនិយោគ និងជំរុញកិច្ចសហប្រតិបត្តិការមួយរវាងកម្ពុជា និងចិន ព្រមទាំងដៃគូសេដ្ឋកិច្ចនានា។ ដោយឡែងក្នុងឆ្នាំនេះ សម្តេចតេជោ ហ៊ុន សែន ក៏បានចូលរួមដូចសព្វមួយដង។

ឆ្នាំនេះកម្មវិធីពិព័រណ៍អាស៊ាន-ចិន គឺជាកម្មវិធី លើកទី១៥ ហើយ ព្រឹត្តិការណ៍សំខាន់ គឺផ្សព្វផ្សាយអំពីកិច្ចសហប្រតិ-បត្តិការជាមិត្តភាពរវាង ចិន និងអាស៊ាន និងជំរុញបើកផ្លូវទៅរកការស្ថាបនានូវគំនិតផ្តួចផ្តើមផ្លូវសូត្រសមុទ្រសតវត្សរ៍ទី២១ ដោយបង្ហាញអំពី គំនិតច្នៃប្រឌិតលើបច្ចេក-វិទ្យាព័ត៌មាន ជាពិសេសគឺបច្ចេកវិទ្យាវៃឆ្លាត ពង្រឹងកិច្ចសហប្រតិបត្តិការ ទ្វេភាគីលើផ្នែកឧស្សាហកម្ម និងផលិតកម្ម។

កម្មវិធីនេះ ក៏ជាឱកាសដែលផលិតករលើគ្រប់វិស័យនៃប្រទេសចិន និងបណ្តាប្រទេសអាស៊ាន នាំយកនូវគម្រោងផលិតកម្ម ផលិតផល មកតាំងបង្ហាញដើម្បីលក់ និងដើម្បីស្វែងរកដៃគូ សហប្រតិបត្តិការ វិនិយោគ ពង្រីកអាជីវកម្ម។ល។ សម្រាប់កម្ពុជា ក៏ដូចជាពាណិជ្ជករមក ពីប្រទេសអាស៊ានទាំងអស់ គឺតែងតែត្រូវបានចូលរួមនៅក្នុងកម្មវិធីនេះជាបន្តបន្ទាប់ ដោយអ្នកដែលចូលរួម មានតាំងពីក្រុមហ៊ុនវិនិយោគធំៗ ដែលកំពុងតែបណ្តាក់ទុនលើផ្នែកសំណង់ ស្ថាបត្យកម្ម កសិកម្ម... រហូតដល់ ពាណិជ្ជករតូចៗ ដែលមានស្នាដៃយកផលិតផលទៅលក់ នៅក្នុងពិព័រណ៍នេះផងដែរ។

ក្រៅពីពាណិជ្ជករ អ្នកសារព័ត៌មាន និងមន្ត្រីរាជរដ្ឋាភិបាល ជាច្រើនស្ថាប័នក៏ត្រូវបានអញ្ជើញ ចូលរួមសិក្សាស្វែងយល់ អំពីកម្មវិធីនេះជារៀងរាល់ឆ្នាំផងដែរ។

នាឆ្នាំនេះកម្មវិធីពិព័រណ៍អាស៊ាន-ចិន លើកទី១៥នេះ គឺបានប្រារព្ធឡើងរយៈពេល ៤ថ្ងៃ ដូចសព្វមួយដង ពោលគឺពីថ្ងៃទី ១២ ដល់ថ្ងៃទី១៥ ខែកញ្ញា នៅមជ្ឈមណ្ឌលតាំងពិព័រណ៍ និងសន្និសីទអន្តរជាតិ ដែលប្រទេសចិនបានកសាងឡើងមានទំហំដ៏ធំនៅលើផ្ទៃដីសរុបចំនួន ១០០.៤០០ម៉ែត្រ-ការ៉េ ដោយមានសាលពិព័រណ៍ដ៏ធំ និងមានកន្លែងរៀបចំព្រះពន្លាចំនួនដល់ទៅ ៥កន្លែង។

ព្រះពន្លាទាំងនោះ គឺរួមមាន ទីមួយ ព្រះពន្លាសម្រាប់ពាណិជ្ជកម្មលក់រាយ ដែលមានតាំងពី អាហារ ភេសជ្ជៈរបស់ប្រើប្រាស់ វត្ថុធាតុដើម ផលិតផលគ្រឿងម៉ាស៊ីន យានយន្ត... សម្ភារអគ្គិសនី និងអេឡិច-ត្រូនិចជាដើម។ ព្រះពន្លាទីពីរ គឺព្រះពន្លាកិច្ចសហប្រតិបត្តិការវិនិយោគជាសាលសម្រាប់ស្វែងរកកិច្ចសហប្រតិបត្តិការកសាងសមត្ថភាពឧស្សាហកម្ម និងសេដ្ឋ-កិច្ច។ កន្លែងនោះ គឺជាកន្លែង ដែលចុះហត្ថលេខា រៀបចំសន្និសីទធំៗ លើផ្នែកគម្រោងកុងត្រាអន្តរជាតិតំបន់ ហើយជាមជ្ឈមណ្ឌលតាំងពិព័រណ៍ផលិតផលរបស់ចិនមកពីខេត្តចំនួន១៥។ ព្រះពន្លាទី ៣ ត្រូវបានគេដឹងថា គឺជាព្រះពន្លា សម្រាប់វិស័យបច្ចេកវិទ្យាជាន់ខ្ពស់ ដែលមានតាំងពីវិទ្យាសាស្ត្រ កម្មវិធីច្នៃប្រឌិតទីក្រុងវៃឆ្លាត កម្មវិធីសហគ្រាស់បច្ចេកវិទ្យាឧស្សាហកម្ម និង សេវាកម្មសុខភាព រហូតដល់បច្ចេកវិទ្យាគ្រប់គ្រងអាកាសធាតុ និងការកែច្នៃកាកសំណល់ឡើងទៅ។ ទីបួន គឺព្រះពន្លាសម្រាប់ពាណិជ្ជកម្មសេវាកម្ម ដែលមានតាំងពី សេវាកម្មហិរញ្ញវត្ថុ ធានារ៉ាប់រងសេវាកម្មទេសចរណ៍ សេវាកម្មជាច្រើនទៀត។ និងទី៥ គឺព្រះពន្លាសម្រាប់ទីក្រុងដែលស្រស់ស្អាត ដែលនោះក្នុងនោះ គឺជាកន្លែងសម្រាប់ ប្រទេសចិន និងអាស៊ានទាំង១០ រៀបចំរចនា ដើម្បីយកទីក្រុងណាមួយនៅក្នុងប្រទេសរបស់គេរៀងៗខ្លួនយកមកតាំងបង្ហាញបង្អួតអ្នកចូលរួមទាំងអស់ នៅក្នុងគោលបំណង ជំរុញផ្សព្វផ្សាយទីក្រុងនោះ ទៅដល់ភ្ញៀវទេសចរនានា ។

តាមរយៈកម្មវិធីនេះ យើងឃើញថា កម្ពុជាបានកសាងកេរ្តិ៍ឈ្មោះដ៏ល្អ ទីផ្សារទេសចរ និងវិនិយោគទុនចិន ដោយមកដល់ពេលនេះ ប្រទេសកម្ពុជាបានទាក់ទាញគម្រោងវិនិយោគពីចិន គិតត្រឹមឆ្នាំ២០១៧ គឺប្រមាណជាជាង ១២ពាន់លានដុល្លារ។ នេះបើតាមតួលេខ លោក សុង ប៉ុ ឯងអគ្គរដ្ឋទូតចិនប្រាប់ប្រព័ន្ធផ្សព្វផ្សាយរដ្ឋកាលពីពេលថ្មីៗកន្លងទៅនេះ៕

*ដោយ អរិយបុត្រ*



# សម្តេចតេជោ ហ៊ុន សែន បញ្ជាក់អំពីដំណើរទៅទីក្រុងញូវយ៉ក និងបរទេសនៅខែកញ្ញា និងតុលា

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានមានប្រសាសន៍ក្នុងពិធីជួបសំណេះសំណាលជាមួយកម្មករនិយោជិត ជិត៣ម៉ឺន នាក់នៅខេត្តកំពង់ស្ពឺនាព្រឹកថ្ងៃទី១៩ ខែកញ្ញា បញ្ជាក់អំពីដំណើរទៅទីក្រុងញូវយ៉ក និងបរទេសជាច្រើនគោលដៅ និងច្រើនកម្មវិធី ពីខែកញ្ញាដល់ខែតុលា ឆ្នាំ២០១៨។

នាអំឡុងពេលអញ្ជើញជួបសំណេះសំណាលជាមួយកម្មករ កម្មការិនីប្រមាណ ២៧,៨៤៤នាក់ មកពីរោងចក្រសហគ្រាសចំនួន២៤ ដែលកិច្ចសំណេះសំណាលនេះបានធ្វើឡើងនៅភូមិស្វាយទាប ឃុំអង្គពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា នាថ្ងៃទី២៧ ខែកញ្ញា សម្តេចនឹងហោះទៅកាន់ទីក្រុងញូវយ៉កដើម្បីចូលរួមកិច្ចប្រជុំអង្គការសហប្រជាជាតិ។ ហើយនៅថ្ងៃទី២៨ នឹងជួបជាមួយនឹងលោកនាយករដ្ឋមន្ត្រី ២ប្រទេស បន្ទាប់មកនឹងថ្លែងសុន្ទរកថា នៅអង្គការសហប្រជាជាតិ ហើយនៅម៉ោង៥ល្ងាច គឺនឹងជួបជាមួយនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍បន្តទៀតថា តមកសម្តេចនឹងជួបជាមួយបងប្អូនខ្មែរនៅអាមេរិក។ ហើយនៅខែតុលា សម្តេចនឹងចេញទៅជប៉ុន ចូលកិច្ចប្រជុំកំពូលមេគង្គ ជប៉ុន ហើយហោះទៅចូលរួមប្រជុំមួយនៅឥណ្ឌូនេស៊ី ហើយនឹងបន្តទៅទីក្រុង ប្រ៊ុចសែលប្រទេសប៊ែលហ្សិក ដើម្បីចូលរួមកិច្ចប្រជុំកំពូលអឺរ៉ុប-អាស៊ាន ។

សម្តេចតេជោ ហ៊ុន សែន បញ្ជាក់ថា " ខ្ញុំទៅអង្គការសហប្រជាជាតិលើកនេះមិនមែនចង់និយាយពីបញ្ហាអ្វីទេខ្ញុំនឹងនិយាយពីបញ្ហាពិភពលោកតែប៉ុណ្ណោះ។ ខ្ញុំមិននិយាយអំពីបញ្ហាផ្ទៃក្នុងរបស់កម្ពុជានោះទេ។ ខ្ញុំក៏ចង់ ប្រាប់ផងដែរថា កម្ពុជាក៏មានកម្លាំងអាចជួយដល់អង្គការសហប្រជាជាតិក្នុងការថែរក្សាសន្តិភាពនៅលើពិភពលោក។ យើងក៏នឹងបើកចំហរឲ្យប្រទេសនៅលើពិភពលោកមករៀននៅកម្ពុជាអំពីការដោះមីន។ យើងមានមជ្ឈមណ្ឌលមីនអាស៊ានមួយនៅកម្ពុជា ដូចនេះប្រទេសផ្សេងៗអាចមកសិក្សានៅទីនេះបាន"។ សម្តេចតេជោ នាយករដ្ឋមន្ត្រីបានថ្លែងទៀតថា "ខ្ញុំទៅអង្គការសហប្រជាជាតិមិនមែនដើម្បីនិយាយបញ្ហាកម្ពុជាទេតែនិយាយអំពីបញ្ហាពិភពលោក"។

សម្តេចតេជោ ហ៊ុន សែន បានបន្តថា គ្មានអ្នកណាអាចដាក់គំនាបមកលើកម្ពុជាបាននោះទេ ដោយសារប្រទេសនេះមានច្បាប់មានអធិបតេយ្យភាព។ ដូច្នេះប្រទេស គឺត្រូវតែអនុវត្តតាមច្បាប់របស់ប្រទេសមិនអាចទៅតាមច្បាប់របស់ប្រទេសណាមួយនោះទេ ៕

# កម្ពុជានៅតែជាប្រទេសមានធនធានធម្មជាតិច្រើនជាងគេនៅលើពិភពលោក

យោងតាមអង្គការសត្វនិងរុក្ខជាតិព្រៃអន្តរជាតិ (FFI) ដែលជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយកំពុងធ្វើការនៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាង ២០ឆ្នាំមកហើយនោះ បានឲ្យដឹងថា ប្រទេសកម្ពុជាគឺជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសដែលសំបូរជីវៈចម្រុះនៅក្នុងពិភពលោកជាពិសេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

ប្រទេសកម្ពុជាត្រូវបានគេជឿជាក់ថាជាជម្រករបស់ជីវចម្រុះប្រមាណជា ៨.២៦០ប្រភេទ រួមជាមួយសត្វផ្សោត និងសត្វល្មូនជាង២៥០ប្រភេទ, ប្រភេទត្រីចំនួន ៨៧៤ ប្រភេទ និងប្រភេទបក្សីជាង ៥០០ ប្រភេទ ។

ការចាប់អារម្មណ៍ជាពិសេសចំពោះអ្នកអភិរក្សគឺមានផ្ទៃដីទំហំ ១០.០០០គីឡូម៉ែត្រការ៉េ នៅភាគនិរតីនៃប្រទេសដែលគេស្គាល់ថាជាទេសភាពភ្នំក្រវាញដែលមានសត្វជាច្រើនប្រភេទដែលរួមមានសត្វដំរី ខ្លាឃ្មុំ ជាដើម។

អង្គការនេះ បានអះអាងថា វានៅមិនទាន់ត្រូវបានគេរកឃើញអស់នៅឡើយទេនូវទេសភាព និងអាថ៌កំបាំងជាច្រើន នៅក្នុងប្រព័ន្ធជីវៈចម្រុះនៅកម្ពុជា។

ប្រទេសកម្ពុជាក៏មានបរិស្ថានសមុទ្រដ៏សម្បូរបែបផងដែរ ដោយថ្មប៉ប្រះទឹក ផ្កាថ្មជុំវិញកោះស្ទើរតែទាំងអស់។ ប្រហែល ៧០ប្រភេទសត្វផ្កាថ្មត្រូវបានគេរកឃើញនៅទីនេះហើយប្រទេសក៏មានវាលស្មៅសមុទ្រធំៗ និងជម្រកព្រៃកោងកាងផងដែរ។

ដូចបណ្តាប្រទេសដទៃទៀតនៅក្នុងតំបន់ដែរប្រទេសកម្ពុជាប្រឈមមុខនឹងបញ្ហាប្រឈមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួននិងកាត់បន្ថយភាពក្រីក្រដោយគ្មានការបំផ្លិចបំផ្លាញធនធានធម្មជាតិដែលជាធនធាន តែមួយគត់របស់ខ្លួន ៕

# កម្ពុជានៅត្រូវការសណ្ឋាគារ និងផ្ទះសំណាក់ ១០០.០០០ បន្ទប់ទៀត

ប្រទេសកម្ពុជាត្រូវការយ៉ាងហោចណាស់សណ្ឋាគារ និងផ្ទះសំណាក់ប្រមាណជា ១០០.០០០ទៀត នៅត្រឹមឆ្នាំ២០២៥ ដើម្បីបំពេញតាមនិន្នាការកើនឡើងនៃភ្ញៀវទេសចរជាតិ និងអន្តរជាតិ។

ការព្យាករនេះត្រូវបានចែករំលែកកាលពីពេលថ្មីៗនេះដោយរដ្ឋមន្ត្រីក្រសួងទេសចរណ៍ លោក ថោង ខុន។ លោក រដ្ឋមន្ត្រីបានអំពាវនាវឱ្យមានការវិនិយោគបន្ថែមទៀតនៅក្នុងវិស័យនេះ។

លោករដ្ឋមន្ត្រីបាននិយាយថា "ក្នុងចំណោមបន្ទប់ដែលត្រូវការប្រហែល ៦០.០០០ ត្រូវជាសណ្ឋាគារលំដាប់ខ្ពស់រួមទាំងសណ្ឋាគារលំដាប់ផ្កាយ ៤ និងផ្កាយ ៥"។

នៅឆ្នាំ២០៣០ កម្ពុជារំពឹងថានឹងមានភ្ញៀវទេសចរបរទេសប្រហែល ១៥លាននាក់ហើយប្រទេសនេះនឹងទទួលបានប្រមាណ ៦,២លាននាក់ក្នុងឆ្នាំ២០១៨ និង៧លាននាក់នៅត្រឹមឆ្នាំ ២០២០ ។

ចន្លោះពីខែមករាដល់ខែកក្កដាឆ្នាំ ២០១៨ ប្រទេសកម្ពុជាបានស្វាគមន៍ភ្ញៀវទេសចរអន្តរជាតិចំនួន ៣,៤៥ លាននាក់កើនឡើង ១១,១ ភាគរយបើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ៕

# សម្តេចប៉ាបស្នើឲ្យមន្ត្រីប៉ូលីសអ៊ីតាលីទាំងអស់បំពេញការងារប្រកបដោយអំពើល្អ

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃទី២៩ ខែកញ្ញា បានជួបជាមួយនឹងមន្ត្រីប៉ូលីស ដែលតំណាងសមាគមប៉ូលីសជាតិរបស់អ៊ីតាលី ដែលមានចំនួនសរុបទាំងអស់រហូតដល់ទៅ ៧០០០នាក់។

យោងទៅតាមវិទ្យុវ៉ាទីកង់ បានឲ្យដឹងថា នៅក្នុងជំនួបនោះ សម្តេចប៉ាបបានជំរុញឲ្យមន្ត្រីប៉ូលីសអ៊ីតាលីទាំងអស់ប្តេជ្ញាបំពេញភារកិច្ចប្រកបដោយឆន្ទៈនិងសកម្មភាពល្អ។

សម្តេចប៉ាប បានស្នើឲ្យមន្ត្រីប៉ូលីសទាំងអស់ឲ្យពង្រីកការងារទទួលខុសត្រូវសម្រាប់ពលរដ្ឋ ហើយក៏ត្រូវយកចិត្តទុកដាក់ជួយយកអាសារប្រជាពលរដ្ឋសាសន៍ដ៏ទៃ ដើម្បីផ្សព្វផ្សាយ និងចែករំលែងនូវ ភាពស្របច្បាប់ ការគោរព និងសន្តិសុខសណ្តាប់ធ្នាប់ល្អតាមការប្តេជ្ញាចិត្តថា និងអនុវត្តភារកិច្ចតាមបទបញ្ជានិងការប្តេជ្ញាចិត្តរបស់មន្ត្រីប៉ូលីស ដែលបានចូលរួមនៅក្នុងសមាគមនេះ។

រហូតមកដល់ពេលនេះ គេដឹងថា សមាគមប៉ូលីសជាតិអ៊ីតាលីនេះ ត្រូវបានគេដឹងថា មានទាំងមន្ត្រីប៉ូលីសនៅក្នុងតំណែង និងការទទួលខុសត្រូវ និងមន្ត្រីប៉ូលីសដែលបានចូលនិវត្តន៍ ដើម្បីចែករំលែកនូវមនោគមវិជ្ជា និងប្រពៃណី របៀបរបបការងាររបស់មន្ត្រីប៉ូលីសរដ្ឋ និងជាតិអ៊ីតាលី។

សម្តេចប៉ាបបានលើកទឹកចិត្តដល់មន្ត្រីប៉ូលីសនៅក្នុងសមាគមទាំងអស់ ត្រូវជួយសម្របសម្រួល ក៏ដូចជាយកចិត្តទុកដាក់នឹងសុខទុក្ខរបស់ប្រជាពលរដ្ឋ។

សម្តេចប៉ាបក៏បានលើកទឹកចិត្តពួកគេ ឲ្យបើកចំហរនឹងប្តេជ្ញាចិត្តនៅក្នុងការធ្វើអ្វីដែលមានប្រយោជន៍ ការពារគោលការណ៍មូលដ្ឋានរបស់សមាគម និងប្រជាពលរដ្ឋក៏ដូចជាជនជាតិនានា។

សម្តេចប៉ាបបានថ្លែងថា សមាគមនេះ គឺដូចជាគ្រួសារមួយ ដែលជាបណ្តុំនៃគ្រប់សាសន៍ ដែលអាចនឹងស្ថិតស្ថេរបាន ដោយសារតែផលប្រយោជន៍របស់មនុស្សទាំងអស់មានការគោរពគ្នាទៅវិញទៅមក។ល។

សម្តេចប៉ាបបានថ្លែងទៀតថា សង្គមដែលល្អ គឺសង្គមដែលមានការស្វាគមន៍គ្រប់ជាតិសាសន៍ដើម្បីផ្សព្វផ្សាយនូវវប្បធម៌នៃភាពស្របច្បាប់ និងសណ្តាប់ធ្នាប់ ៕

# ពលរដ្ឋសាមញ្ញាស្ទាក់ស្ទើរនៅក្នុងការស្វាគមន៍ការហូរចូលនៃវិនិយោគិ



ខណៈដែលវិនិយោគគិន និងទេសចរជនជាតិចិននៅតែបន្តមានការកើនឡើងនៅក្នុងទីផ្សារវិនិយោគ និងទេសចរណ៍នៅកម្ពុជា ប្រជាពលរដ្ឋកម្ពុជាសាមញ្ញខ្លះហាក់មានអារម្មណ៍ស្ទាក់ស្ទើរនៅក្នុងការស្វាគមន៍ ពួកគេ ប៉ុន្តែអ្នកខ្លះថា នេះគឺជានិន្នាការសាកល ដោយសារកំណើននៃការហូរចូលនៃជនជាតិចិន គឺកើនឡើងសឹងតែគ្រប់ទីកន្លែង។

លោក វិន ចិន្តា ជាអ្នកទេសចរនៅក្នុងសុក្រមួយរូប បានឲ្យដឹង នៅខេត្តសៀមរាប ខណៈនាំគ្រួសារមក កម្សាន្តលេងនៅខេត្តសៀមរាប កាលពីពេលថ្មីៗនេះ បានអះអាងថា លោកមានការភ្ញាក់ផ្អើលនឹងវត្តមានជនជាតិចិននៅកម្ពុជា។

លោកបានបញ្ជាក់ថា "ដំបូងខ្ញុំគិតថាជនជាតិចិនទៅតែកំពង់សោម (ខេត្តព្រះសីហនុ) ទេ មើលទៅ ប៉ុន្តែសូម្បីតែសៀមរាបក៏សំបូរដែរ"។

លោកបានបញ្ជាក់ទៀតថា "នៅមុខអង្គរ មុខប្រាសាទបាយ័ន មុខប្រាសាទបន្ទាយ-ស្រី ហើយសូម្បីតែនៅសណ្ឋាគារខ្ញុំស្នាក់នៅ ហើយនៅ ផាប់ស្ទ្រីត ដែលជាកន្លែងពេញនិយមសម្រាប់ពួក លោកខាងលិចនោះ ក៏គឺសុទ្ធតែចិនតែម្តង។ ពួកលោកខាងលិច និងសាសន៍ដ៏ទៃ គឺមិនសូវឃើញទេឥឡូវ"។

តាមប្រសាសន៍របស់លោកចិន្តា ពីដំបូងលោក និងគ្រួសារមិនទាន់មានចំណាប់អារម្មណ៍នឹងមកខេត្តសៀមរាបនៅឡើយទេ ។ គោលដៅនៃទេសចរណ៍លក្ខណៈគ្រួសាររបស់លោក គឺនៅខេត្តព្រះសីហនុឯណោះទេ ដោយសារតែកូនៗរបស់លោក

## អ្នកទេសចរណ៍ចិនរំពឹងថា នឹងបន្តមកកម្ពុជាបន្ថែមទៀត

តាមការរំពឹងទុករបស់មន្ត្រីក្រសួងទេសចរណ៍បានអះអាងថា នៅក្នុងឆ្នាំ២០១៨ នេះកម្ពុជានឹងបន្តទាក់ទាញកំណើនភ្ញៀវទេសចរពីប្រទេសចិនថែមទៀត ពោលគឺប្រមាណជាជិត ២លាននាក់ ក្រោយពេលដែលរយៈពេល ៦ខែដើមឆ្នាំនេះនៅក្នុងចំណោមភ្ញៀវទេសចរអន្តរជាតិជាង ៣លាននាក់ គឺកម្ពុជាបានទាក់ទាញចិន បានជិត ១លាននាក់ហើយនោះ ។

តាមសេចក្តីប្រកាសរបស់ក្រសួងទេសចរណ៍ កាលពីពេលថ្មីៗនេះ បានឲ្យដឹងថា ទន្ទឹមនឹងកំណើននៃ ភ្ញៀវទេសចរចិនកម្ពុជាកំពុងតែប្រឈមមុខនឹងការធ្លាក់ចុះនៃភ្ញៀវទេសចរមកពីទីផ្សារផ្សេងៗនៅក្នុងតំបន់ ដូចជា អាស៊ាន កូរ៉េ ជប៉ុន និងអ្នកទេសចរណ៍មកពីបច្ចឹមប្រទេស ។

ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនេះលោកថោងខុនរដ្ឋមន្ត្រីក្រសួងទេសចរណ៍បានជំរុញឲ្យមន្ត្រីរបស់ក្រសួងសហការជាមួយអ្នកដែលពាក់ព័ន្ធដើម្បីពិនិត្យនិងរកវិធីសាស្ត្រដើម្បីបន្តទាក់ទាញភ្ញៀវទេសចរចម្រុះជាតិសាស្ត្រដើម្បីនិរន្តរភាពនៃវិស័យទេសចរដែលគេដឹងថាគឺជាសសរស្តម្ភមួយដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជា។

ធនាគារអភិវឌ្ឍន៍អាស៊ីបានព្យាករណ៍ថាប្រទេសកម្ពុជានឹងមានកំណើនសេដ្ឋកិច្ចប្រមាណ៧,០% សម្រាប់ឆ្នាំ២០១៨ និង២០១៩ដោយឡែកវិស័យទេសចរណ៍កម្ពុជាកំពុងតែបានបន្តកើនឡើងដែលមួយផ្នែកធំដោយសារកំណើនចំនួនភ្ញៀវទេសចរមកពីចិន។

បច្ចុប្បន្ននេះក្រុមហ៊ុនអាកាសចរណ៍ចិនចំនួន ១៦ ក្រុមហ៊ុនកំពុងប្រតិបត្តិការហោះហើរត្រង់ពីចិនទៅកម្ពុជា ហើយក្រុមហ៊ុនអាកាសចរណ៍ AirChinaនឹងបើកជើងហោះហើរត្រង់ពីប៉េកាំងទៅភ្នំពេញ ដោយចាប់ផ្តើមនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ ខាងមុខនេះបន្ថែមទៀត៕

# នចិន ខណៈវិនិយោគិននិងទេសចរចិនមានការកើនឡើងយ៉ាងគំហុក


Photo : Supply

ចូលចិត្តលេងទឹក ប៉ុន្តែដោយសារតែទីនោះល្បីល្បាញថាសម្បូរជនជាតិចិន ហើយរបស់របរហូបចុក ជាពិសេសគឺកន្លែងស្នាក់នៅវាថ្លៃហើយមិនសូវចូលចិត្តឥរិយាបទរបស់ភ្ញៀវទេសចរជនជាតិចិនខ្លះផងនោះ ក៏ស្រុះស្រួលគ្នាថា មកខេត្តសៀមរាបនេះវិញ ប៉ុន្តែលោកបានអះអាងថា គឺនៅតែឃើញ និងជួបភ្ញៀវទេសចរជនជាតិចិនជាច្រើនដដែល។

លោកបន្តទៀតថា សម្រាប់អារម្មណ៍របស់លោកវាមិនជាស្អីទេ ប៉ុន្តែគ្រាន់តែថាមិនសូវចូលចិត្តចរិត និងឥរិយាបទរបស់ជនជាតិចិនមួយចំនួន ដោយសារតែពួកគេរាងប្រងើងប្រងាងបន្តិច ។

លោក ទេស សារឹម ជាអ្នកបើករថយន្តដឹកភ្ញៀវទេសចរមួយរូប បានឲ្យដឹងថា ភ្ញៀវទេសចរចិន មកច្រើនមែនទែនឆ្នាំនេះ។

លោកបានបញ្ជាក់ថា "នៅភ្នំពេញ នៅខេត្តសៀមរាប នៅកំពង់សោម គឺចិនចុះមកទាំងឡានៗ។ ពេលខ្លះ ក្រុមហ៊ុនឲ្យខ្ញុំទៅទទួលនៅព្រលានយន្តហោះ ពីឡានក្រុងក៏មានដែរ។ ដើរចេញពីព្រលានយន្តហោះមក ឃើញចិនឡើងព្រាត"។

លោកបានបន្តទៀតថា សព្វថ្ងៃនេះលោកបានបើករថយន្តនេះ សឹងតែ ៧០ ភាគរយហើយ គឺដឹកតែជនជាតិចិនតែប៉ុណ្ណោះ សាសន៍ដ៏ទៃ ដូចជា បារាំង អាមេរិក អង់គ្លេស ជប៉ុន កូរ៉េ គឺមិនសូវជាមានច្រើនទេ ហើយលោកដឹកឡើងវិលជុំវាំងភ្នំពេញ សៀមរាប និងខេត្តព្រះសីហនុ ហើយខ្លះក៏ទៅដល់ភូមិភាគឥសាន្តថែមទៀតផង។

ទាក់ទិននឹងឥរិយាបទរបស់ភ្ញៀវទេសចរជនជាតិចិន និងជនជាតិដ៏ទៃ លោក សារឹម ហាក់ស្ទាក់ស្ទើរនៅក្នុង ការអះអាងថា ពួកគេយ៉ាងម៉េច ដោយគ្រាន់តែនិយាយខ្លីថា "បងដឹងស្រាប់ហើយ ថាវាយ៉ាងម៉េច ប៉ុន្តែយើងជាអ្នកផ្តល់សេវាកម្មឲ្យគេ វាមិនជាស្អីទេ"។

លោកបានបន្តទៀតថា បណ្តាភ្ញៀវទេសចរចិនដែលលោកបានដឹក ភាគច្រើនគឺចាយលុយខ្លាំងគួរសម ហើយពេលខ្លះលោកមានអារម្មណ៍ថា ដូចជាច្រើនជាងពួកលោកខាងលិច ដែលធ្លាប់ដឹកផង។ ពួកគេ មកដេកសុទ្ធតែសណ្ឋាគារផ្កាយ ដូចជាសុខា ជាដើម ហើយហូបចុកវិញក៏នៅហាងល្អៗដែរ ហើយបើចូលហាងលក់វត្ថុអនុស្សាវរីយ៍វិញ គឺដូចជា មានអារម្មណ៍ថា ពេលខ្លះពួកគេចាយលុយដូចជាអត់សូវស្តាយម៉េចទេ។

មគ្គុទ្ទេសក៍ទេសចរមួយរូប ដែលមិនបញ្ចេញអត្តសញ្ញាណ បានឲ្យដឹងថា ភ្ញៀវទេសចរចិន ភាគច្រើនគឺមកជាក្រុមៗពោល គឺមិនដែលក្រោមមួយឡានទេ ហើយកម្រដើរទេសចរណ៍ជារបៀបផ្សងព្រេងដូចជាពួកលោកខាងលិច ដែលដើរជាឯកជនម្នាក់ ឬពីរនាក់ស្ពាយតែសាក់កាដូម្នាក់មួយដើរពេញប្រទេសណាស់។

លោកបានបញ្ជាក់ថា "រឿងទេសចរណ៍សាក់កាដូសម្រាប់ភ្ញៀវចិន គឺគ្មានតែម្តងពួកគេមកទាំងក្រុមៗ ស្នាក់នៅសណ្ឋាគារល្អៗ តែជួនកាលវាឆ្ងងឆាង ប្រឡាំប៉ាមប៉ាកបន្តិច"។

មគ្គុទ្ទេសក៍ទេសចររូបនោះ បានអះអាងថា ភ្ញៀវទេសចរចិនភាគច្រើនមិនពិបាករឿងលុយរឿងកាក់ទេ ប៉ុន្តែលំបាករឿងសុជីវធម៌ ហើយឆេវឆាវ ហើយបើដើរជាមួយពួកគេគឺត្រូវធ្វើចិត្តឲ្យធ្ងន់បន្តិច។

លោកបានបញ្ជាក់ថា "កំពុងតែបាយៗអីហ្នឹងពេលខ្លះ ទាស់សម្តីគ្នាតែបន្តិចអីហ្នឹងគប់ចាន គប់ស្លាបព្រាជាក់គ្នាក៏មានដែរ"។

ដោយឡែក លោក ជាង សុខហួរ ជាអាជីវករ និងជាអ្នកដែលជាប់នឹងខ្សែស្រឡាយចិនមួយរូប បានឲ្យដឹងថា ឥរិយាបទជនជាតិចិនមួយចំនួន គឺភាគច្រើនមិនដូចជាគេល្បីចឹងទេ ដោយសារតែពួកគេចូលចិត្តនិយាយឮ និយាយរាងប្រងើងប្រងាង មិនសូវជាចេះសុជីវធម៌ទេ ប៉ុន្តែពួកគេមិនអាក្រក់នោះទេ។

លោកបានបន្តទៀតថា គ្រប់ជនជាតិទាំងអស់នរណាក៏មានអាក្រក់មានល្អដែរ ដូច្នេះកុំវិនិច្ឆ័យទាំងអស់ៗ ហើយនាំគ្នាមិនសូវចូលចិត្តចិននោះ។ លោកបានបញ្ជាក់ថា "បើគេមកយកលុយមកលេងស្រុកយើង ហើយចាយនៅស្រុកយើង មករកស៊ីនៅស្រុកយើងស្វាគមន៍គេទៅ ហើយបើពួកអាក្រក់ៗ ប្រងើងប្រងាងដាក់ទោសទៅ ស្រុកយើងមានច្បាប់តាស់"។

ទាក់ទិននឹងការកើនឡើងនូវវត្តមានជនជាតិចិន ទាំងទេសចរ និងវិនិយោគិន បច្ចុប្បន្ននេះ គឺជាព័ត៌មានក្តៅគគុកមួយនៅតាមបណ្តាញព័ត៌មាននានា ជាពិសេសនៅលើបណ្តាញសង្គម។ មានការពិភាក្សា និងបញ្ចេញទស្សនៈផ្សេងៗគ្នាជាច្រើន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយអ្នកវិភាគឯករាជ្យមួយរូប បានមានប្រសាសន៍ថា វត្តមានរបស់ជនជាតិចិននៅកម្ពុជា គឺមិនមែនជារឿងកម្ពុជាតែមួយទេនេះ គឺជារឿងរបស់ពិភពលោក។

លោកបានអះអាងថា វត្តមាននៃកំណើនភ្ញៀវទេសចរ និងវិនិយោគិនចិន គឺមានការកើនឡើងគ្រប់កន្លែងមិនថា តែកម្ពុជាប្រទេសអាស៊ានមានថៃ ម៉ាឡេស៊ី វៀតណាម ឡាវ ភូមា... សូម្បីតែទីផ្សារនៅអឺរ៉ុប អាមេរិក អាហ្វ្រិក អូស្ត្រាលី នូវែលហ្សេឡង់ អីគឺសុទ្ធតែចិន។

លោកបានបញ្ជាក់ទៀតថា សូម្បីតែទីផ្សារទេសចរណ៍នៅបារាំង និងអឺរ៉ុបមួយចំនួនក៏ត្រូវបានគេតម្រូវឲ្យមានការរៀបចំភាសា និងសេវាកម្មផ្សេងៗ ដើម្បីទាក់ទាញចិនដែរ នោះមិនរួមបញ្ចូលនៅអាមេរិកដែលមានជាសហគមន៍ចិនដ៏ល្បីល្បាញឆាយណាថោន នៅតាមរដ្ឋសំខាន់ៗធំៗនៅអាមេរិកផងនោះទេ។

កាលពីឆ្នាំ២០១៧ អង្គការពាណិជ្ជកម្មពិភពលោកបានអះអាងថា ប្រជាពលរដ្ឋចិនចំនួន ១៤២ លាននាក់ បានចំណាយលុយរបស់ពួកគេ ២៥៨ ពាន់លានដុល្លារដើរលេងជុំវិញពិភពលោក។ ការចំណាយរបស់ពួកគេ គឺខ្ពស់ជាងជនជាតិអាមេរិកទៅទៀត ដោយពលរដ្ឋអាមេរិក គឺចំណាយលុយត្រឹមតែ ១៣៥ពាន់លានដុល្លារ ប៉ុណ្ណោះ។

ដោយ អរិយបុត្រ

## វិនិយោគិនចិនក៏ត្រូវបានគេរំពឹងថា នឹងបន្តកើនឡើងផងដែរ

នៅក្នុងដំណើររបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីទៅចូលរួម បើកពិព័រណ៍ចិន-អាស៊ាន លើកទី១៥ ក្រោមប្រធានបទ "រួមគ្នាកសាងវិថីសូត្រសមុទ្រសតវត្សរ៍ទី២១ បង្កើតសមាគមន៍ចិន-អាស៊ានប្រកបដោយនវានុវត្តន៍" កាលពីពាក់កណ្តាលខែកញ្ញា ក្រុមហ៊ុនចិនជាច្រើនបានស្វះស្វែងទទួលព័ត៌មានពីទីផ្សារនៅកម្ពុជា។

តាមរយៈការផ្សព្វផ្សាយជាសាធារណៈពីបណ្តាញសង្គមផ្លូវការរបស់សម្តេចតេជោ បានឲ្យដឹងថា អំឡុងពេលនៃការស្នាក់នៅទីក្រុងណាន់នីងនៃតំបន់ស្វយ័តជនជាតិជ័ងក្វាងស៊ី សម្តេចបានទទួលជួបសវនាការ ជាមួយនឹងប្រធាន និងតំណាងក្រុមហ៊ុនចិនជាច្រើន ។

តាមសេចក្តីរាយការណ៍ពីបណ្តាញសង្គមរបស់សម្តេចផ្ទាល់ បានឲ្យដឹងថា សម្តេចតេជោ បានជួបពិភាក្សា ជាមួយនឹងតំណាងក្រុមហ៊ុនចិនធំៗ ចំនួនជាង ១០ក្រុមហ៊ុន ដែលខ្លះកំពុងតែវិនិយោគនៅក្នុងប្រទេសកម្ពុជាស្រាប់ និងខ្លះកំពុងតែស្វែងរកច្រកសម្រាប់វិនិយោគ លើវិស័យកសិកម្ម កំពង់ផែ ថាមពលវារីអគ្គីសនី។ ល។

ប្រភពដដែលបានបន្តថា ដោយឡែកពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងចិនក៏មានការកើនឡើងគួរឲ្យកត់សម្គាល់ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ដោយបានកើនឡើងដល់ ៥,៨ ប៊ីលានដុល្លារអាមេរិក តាមស្ថិតិឆ្នាំ២០១៧ គឺកើនឡើងប្រមាណ ២២% ធៀបនឹងឆ្នាំកន្លងទៅ។ សម្រាប់ការវិនិយោគពីប្រទេសចិនក្នុងរយៈពេលបីឆ្នាំកន្លងទៅនេះបានកើនឡើងពីប្រមាណ ៩០០លានដុល្លារអាមេរិកនៅឆ្នាំ ២០១៦ ដល់ ១,៦ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ ២០១៧ និងក្នុងរយៈពេល ៧ ខែដើមឆ្នាំ ២០១៨ នេះបានកើនដល់ ២,៨ ប៊ីលានដុល្លារអាមេរិក។

# បោះជំរំសម្រាប់ការត្រាស់ហៅ

យុវជន យុវនារី ចំនួនប្រមាណជាង ៣០០នាក់ មកពីព្រះសហគមន៍កាតូលិកភូមិភាគទាំងបីបានជួបជុំគ្នាក្នុងកម្មវិធីបោះជំរំសម្រាប់ការត្រាស់ហៅ លើកទីប្រាំមួយ ក្រោមប្រធានបទ "ព្រះជាម្ចាស់ត្រូវការកូន"។ កម្មវិធីនេះ បានធ្វើនៅព្រះសហគមន៍សន្តមីកាអែល ក្រុងព្រះសីហនុ កាលពីថ្ងៃទី០៦ ដល់ថ្ងៃទី០៩ កញ្ញា ២០១៨។

នៅក្នុងការអប់រំលោកអភិបាលអូលីវីយេ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ លោកបានលើកយកចំណុចសំខាន់ៗមួយចំនួន ដើម្បីបំភ្លឺដល់យុវជនយុវនារីក្នុងការរិះគិតអំពីជីវិតជាអ្នកបួស។ លោកអភិបាលបានលើកចំណុចដូចជា "តើអ្នកមករកអ្វី?" មានន័យឲ្យយើងដឹងថា ព្រះយេស៊ូណែនាំឲ្យយើងដើរតាមផ្លូវនៃសេចក្ដីសុខ និងសុភមង្គល។ "ខ្ញុំស្រេកទឹក" គឺព្រះយេស៊ូណែនាំឲ្យយើងយល់ថា យើងត្រូវការចូលនៅក្នុងដួងចិត្តរបស់យើងយ៉ាងជ្រៅដើម្បីគិតអំពីអនាគត។ លោកក៏បានលើកដែរនូវចំណុច "កុំខ្លាចអី!" គឺព្រះយេស៊ូគង់នៅជាមួយយើងជានិច្ច យើងធ្វើដំណើរទៅមុខបាន ដោយសារយើងមានទីពឹងមួយយ៉ាងពិសេសគឺព្រះយេស៊ូផ្ទាល់។ "តើរូបខ្ញុំមានឋានៈអ្វី?" ព្រះយេស៊ូណែនាំឲ្យយើងទទួលស្គាល់ខ្លួនឯងឲ្យច្បាស់ និងសួរខ្លួនឯងថា តើព្រះជាម្ចាស់ត្រាស់ហៅឲ្យយើងបម្រើព្រះសហគមន៍តាមរបៀបណា? "ឲ្យគេឮដូចម្ដេចកើត បើគ្មាននរណាប្រកាស?" ព្រះយេស៊ូបានចាត់ឲ្យយើងធ្វើជាអ្នក ដែលប្រកាសដំណឹងល្អសម្រាប់បងប្អូនឯទៀតៗ ដើម្បីឲ្យគេបានឮព្រះបន្ទូលរបស់ព្រះជាម្ចាស់។ លោកអភិបាល ក៏បានលើកយកចំណុចមួយទៀតមកបញ្ជាក់ដែរគឺ "ខ្ញុំជាអ្នកបម្រើ" ដោយយកព្រះនាងម៉ារីជាគំរូដែលបានឆ្លើយទៅទេវទូតកាព្រីអែលថា "នាងខ្ញុំជាអ្នកបម្រើរបស់ព្រះជាអម្ចាស់" ព្រះនាងម៉ារីបានយកចិត្តទុកដាក់ដោយចិត្តបម្រើជានិច្ច។ ក្នុងពេលនោះលោកអភិបាលក៏បានដាក់សំណួរឲ្យយុវជនយុវនារីរិះគិតថា តើខ្ញុំមានសុបិនអ្វី មានអត្ថទស្សនៈអ្វី ដែលជាគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ សម្រាប់ព្រះសហគមន៍ និងពិភពលោក?

លោក មួង រស់ ជាបូជាចារ្យមកពីភូមិភាគបាត់ដំបង ជាសមាជិកគណៈកម្មការរៀបចំកម្មវិធី បានលើកយកជីវិតជាការត្រាស់ហៅ ជាប្រធានបទដើម្បីអប់រំក្នុងកម្មវិធីបោះជំរំសម្រាប់ការត្រាស់នេះដែរ។ លោកបាននិយាយថា ការត្រាស់ហៅ គឺជាពាក្យដែលនាំឲ្យយើងយល់អំពីការសម្ដែងអាថ៌កំបាំងរបស់ព្រះជាម្ចាស់ ការគិតថាជីវិតជាការត្រាស់ហៅ ជួយនាំឲ្យយើងមានសេរីភាពនៅក្នុងដួងចិត្ត ហេតុនេះហើយ យើងត្រូវធ្វើជាសាក្សីនៃជំនឿរបស់យើង។

លោកបូជាចារ្យរូបនេះបានបន្តថា ការណែនាំខាងផ្លូវវិញ្ញាណ គឺមានតម្លៃខ្ពស់បំផុត ដើម្បីជួយឲ្យយើងឃើញវត្តមានរបស់ព្រះជាម្ចាស់ក្នុងជីវិតរបស់យើង។ រាល់ពេលដែលយើងបានស្ដាប់ឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺជាពេលសម្រាប់យើងទទួលការត្រាស់ហៅ។

យុវជនយុវនារី ដែលបានចូលរួមកម្មវិធីបោះជំរំសម្រាប់ការត្រាសហៅនេះ មានការយល់ឃើញស្រដៀងគ្នាថា កម្មវិធីមានសារសំខាន់ព្រោះបានជួយឲ្យយុវជនយុវនារីចេះស្ដាប់ការត្រាស់ហៅរបស់ព្រះជាម្ចាស់។ ម្យ៉ាងទៀត កម្មវិធីនេះបានណែនាំឲ្យយុវជនយុវនារីអាចរកឃើញផ្លូវ ដែលយើងជាយុវជនយុវនារីជ្រើសរើសតាមការត្រាស់ហៅរបស់ព្រះជាម្ចាស់។ ជាពិសេសមេរៀនរបស់លោកអភិបាល លោកបូជាចារ្យ និងសក្ខីភាពទាំងអស់ បានជួយដល់យុវជនយុវនារីដែលចង់ឈ្វេងយល់អំពីការត្រាស់ហៅ បានស្គាល់ និងបានឆ្លើយតបតាមតម្រូវការតាមព្រះអំណោយទានរបស់ព្រះជាម្ចាស់៕



ថតដោយៈ សុវណ្ណភូមិ

# យុវនារីចំនួនពីររូបស្ម័គ្រចិត្ត ចូលក្នុងក្រុមអ្នកបួស អ្នកស្រលាញ់ព្រះឈើឆ្កាងនៅកំពង់ចាម

យុវនារីពីររូបនៃព្រះសហគមន៍កោះរការ ស្ម័គ្រចិត្តចូលក្នុងក្រុមដូនជីកាតូលិក នៃក្រុមគ្រួសារ អ្នកស្រឡាញ់ព្រះឈើឆ្កាង ដើម្បីទទួលអប់រំអំពីជីវិតអ្នកបួសក្នុងក្រុមនេះ។ ពិធីអរព្រះគុណព្រះជាម្ចាស់ និងទទួលបេក្ខនារីទាំងពីរបានប្រារព្ធទៅកាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៨ ក្រោមអធិបតីភាពរបស់ លោក អន់តូនីសាមីស៊ូសែរាជ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។

តាមបងស្រី អាញ៉ែស ស្រីសុជាតិ ជាដូនជីកាតូលិកមួយរូបដែលក្នុងគ្រួសារអ្នកស្រឡាញ់ ព្រះឈើឆ្កាង បានឲ្យដឹងថា យុវនារីទាំងពីរនោះ គឺស្រី ឡៃ និងកញ្ញា។ អ្នកទាំងពីរមកពីព្រះសហគមន៍កាតូលិកកោះរការ។ ដូនជីរូបនេះបន្តថា ពួកគាត់ចូលក្នុងដំហានទី១ គឺជា អាស្ពីរ៉ង់ ដើម្បីទទួលការអប់រំ និងឈ្វេងយល់ពីជីវិតអ្នកបួសជាដូនជីកាតូលិក។



បងស្រី សុជាតិ បន្តថា មុនទទួល ឬថ្វាយពាក្យសច្ចាជាដូនជីកាតូលិកក្នុងក្រុមនេះ យុវនារីត្រូវទទួលការអប់រំ ១ឆ្នាំជាអាស្ពីរ៉ង់ បន្ទាប់មក១ឆ្នាំជា ប៉ុស្ទុឡង់ និង២ឆ្នាំជាណូវីស ហើយគឺថ្វាយពាក្យសច្ចាប្រណិធានលើកទី១។ ក្នុងរយៈពេល៤ឆ្នាំ នេះគេត្រូវសិក្សា ប្រមាណជាង១០មុខវិទ្យាបូករួមជាពិសេសអំពីជីវិតរស់នៅជាក្រុម។ ចំពោះការអប់រំនឹងធ្វើនៅកម្ពុជា មានសាស្ត្រាចារ្យ ជាបូជាចារ្យ និងដូនជីកាតូលិក។ បងស្រី សុជាតិ ក៏បានអធិដ្ឋានសម្រាប់ យុវនារីទាំងពីរ សូមព្រះវិញ្ញាណជួយណែនាំប្អូនទាំងពីរ ឲ្យមានកម្លាំង ធ្វើដំណើរ តាមមាគ៌ារបស់ព្រះជាម្ចាស់ ដោយអំណរសប្បាយ និងសេចក្ដីស្រឡាញ់ផង។

ក្រុមដូនជីកាតូលិក គ្រួសារអ្នកស្រឡាញ់ព្រះឈើឆ្កាង បានចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងកំឡុងទសវត្សរ៍ទី៩០ ដោយមានដូនជីនកាតូលិកក្រុមគ្រួសារអ្នកស្រឡាញ់ព្រះឈើឆ្កាងមកពីប្រទេសថៃ មកតាំងនៅក្នុងព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម គឺលោកយាយ សាវីយ៉េ និងលោកយាយប៉េឡាជី។ ក្រោយមកមានយុវនារីចំនួនពីររូបបានចូលក្នុងក្រុមនេះដើម្បីឈ្វេងយល់អំពីជីវិតអ្នកបួសនៃក្រុមគ្រួសារ អ្នកស្រឡាញ់ព្រះឈើឆ្កាងនេះ គឺបងស្រី អាង សង្វាត និងបងស្រីសួន ប៊ុនថាវីន បានថ្វាយពាក្យសច្ចាប្រណិធានលើកដំបូង នៅថ្ងៃទី២១ មីនា ២០០៤។

បន្ទាប់មកមាន បងស្រី ស្រី សុជាតិ បានថ្វាយពាក្យសច្ចាលើកដំបូងនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៧។ ក្រោយមកមានបងស្រី សុខនី ថ្វាយពាក្យសច្ចាប្រណិធាននៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១២។ បន្ទាប់មក បងស្រី ហ៊ីល និងបងស្រី រដ្ឋា បានថ្វាយពាក្យសច្ចាប្រណិធាន ក្នុងក្រុមអ្នកស្រលាញ់ព្រះឈើឆ្កាង ថ្ងៃទី០៥ ឧសភា ២០១៨។ ពេលនេះមានយុវនារីចំនួនពីររូបសុំចូលឈ្វេងយល់ និងទទួលការអប់រំពីជីវិតអ្នកបួសកាតូលិកក្នុងនេះទៀត។

ចំពោះដូនជីពីររូបដែលមកពីប្រទេសថៃនាទសវត្សរ៍ទី៩០ លោកយាយសាវីយ៉េ និងលោកយាយប៉េឡាជី បានវិលត្រលប់ទៅប្រទេសថៃវិញ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨៕

# បំប៉នអប់រំជំនឿនៅព្រះសហគមន៍កំពង់រទេះ

ជារាងរាល់ឆ្នាំ កំឡុងពេលវិសមកាល (វ៉ាកងធំ) ព្រះសហគមន៍តំបន់កំពង់ធំតែងតែរៀបចំកម្មវិធីសិក្ខាសាលាអប់រំជំនឿរយៈពេលពីរសប្តាហ៍ដើម្បីបំប៉នផ្នែកជំនឿដល់កុមារដែលមកពីព្រះសហគមន៍នានាក្នុងខេត្តកំពង់ធំ។

ដោយឡែកក្នុងឆ្នាំនេះប្រធានបទដែលលើកឡើងនៅក្នុងវគ្គបំប៉នអប់រំជំនឿនោះគឺ"ព្រះយេស៊ូស្រឡាញ់យើង" ដែលមានកុមារចំនួនប្រមាណជា៨០នាក់ ចូលរួមមកពីព្រះសហគមន៍កាតូលិក ភូមិប៉ាងម្នាវ ព្រៃកស្បូវ និងកំពង់រទេះ។

កម្មវិធីអប់រំជំនឿនេះគឺធ្វើឡើងកាលពីថ្ងៃទី១៧ ដល់ថ្ងៃទី៣០ ខែកញ្ញាឆ្នាំ២០១៨ នៅព្រះវិហារគង្វាលដ៏សប្បុរសកំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។

កញ្ញា ជា ចន្ទីជាគ្រូអប់រំជំនឿម្នាក់ដែលបានចូលរួម ណែនាំក្នុងកម្មវិធីបំប៉នអប់រំជំនឿនេះបានឲ្យដឹងថា៖ កម្មវិធីនេះត្រូវបានបែងចែកកុមារជា៦ក្រុមផ្សេងៗគ្នាទៅតាមអាយុ និងកម្រិតរបស់ពួកគេ។ ចន្ទីបន្តថា៖ កុមារ ៩០ភាគរយជាកូនគ្រីស្តបរិស័ទ និងកំពុងទទួលអប់រំជំនឿក្នុងព្រះសហគមន៍កាតូលិក។ តាមចន្ទីបានបន្ថែមថា កុមារដែលមកចូលរួមទទួលការអប់រំគឺមានភាពសប្បាយរីករាយ បើទោះបីជាពួកគេត្រូវចំណាយពេលវេលាពេញមួយថ្ងៃក៏ដោយតែអ្វីដែលសំខាន់នោះគឺកុមារចូលចិត្តស្តាប់អំពីព្រះយេស៊ូ។

អ្នកគ្រូអប់រំជំនឿរូបនេះបន្ថែមថា៖ កម្មវិធីនេះ គឺមិនគ្រាន់តែណែនាំកុមារល្បែងយល់អំពីជំនឿតែមួយមុខនោះទេ គឺមានអប់រំកុមារ អំពីការការពារ និងតម្លៃនៃបរិស្ថានផងដែរ ដើម្បីឲ្យពួកគេចេះស្រឡាញ់ និងថែរក្សាបរិស្ថានដែលនៅជុំវិញខ្លួនគេ ដូចព្រះយេស៊ូស្រឡាញ់យើង។

ចំណែកលោកបូជាចារ្យ ម៉ាក ភីធីឡូប៉េស ជាបូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍កាតូលិកក្នុងខេត្តកំពង់ធំបានឲ្យដឹងថា៖ ពេលវេលាវ៉ាកងធំ គឺកុមារទំនេរច្រើនព្រោះគេមិនទៅសាលា។ ហេតុនេះព្រះសហគមន៍រៀបចំកម្មវិធីនេះឡើងគឺដើម្បីទាញកុមារកុំឲ្យគេភ្លេចសៀវភៅ គេមកជួបជុំគ្នាដើម្បីស្តាប់ និងរៀនមេរៀនផ្សេងៗអំពីព្រះយេស៊ូ ជួបជុំមិត្តថ្មីៗ ញ៉ាំអាហាររួមគ្នា គេសិក្សាជាក្រុម ការធ្វើអនាម័យខ្លួនប្រាណ ការចូលរួមសម្អាតបរិស្ថាន និងមានមេរៀនជាច្រើនទៀតដែលមានប្រយោជន៍សម្រាប់ពួកគេ។

លោកបូជាចារ្យបានបន្តទៀតថា៖ ពេលវេលាពីរសប្តាហ៍ គឺមានប្រយោជន៍ខ្លាំងសម្រាប់កុមារទាំងផ្នែកជំនឿ ទាំងសកម្មភាពទូទៅ និងការអប់រំចិត្តផងដែរ។ លោកបន្ថែមទៀតថា៖ ពេលខ្លះយើងម្នាក់ៗចូលចិត្តប្រើពាក្យថា ព្រះយេស៊ូស្រឡាញ់យើង តែពេលខ្លួនយើងមិនដឹងច្បាស់អំពីឫសគល់នៃសេចក្តីស្រឡាញ់នោះវាធំកម្រិតណាឡើយ។ ហេតុនេះតាមរយៈប្រធានបទខាងលើ គឺចង់បង្ហាញប្រាប់ឲ្យកុមារទាំងអស់ដឹងថា អ្វីៗទាំងអស់គឺសុទ្ធតែជាស្នាមព្រះហស្តរបស់ព្រះជាម្ចាស់។ លោកបូជាចារ្យបន្តថា ព្រះយេស៊ូស្រឡាញ់ដោយសុខចិត្តលស់បាបមនុស្សលោកគឺ សុខចិត្តបូជាព្រះជន្មដោយមិនហារស្តី។ ព្រះយេស៊ូក៏បានប្រៀនប្រដៅមនុស្សអំពីសេចក្តីស្រឡាញ់ជាច្រើន។ ហេតុនេះយើងបង្រៀនឲ្យកុមារចេះយកគំរូតាមព្រះយេស៊ូ គឺរស់នៅជាមនុស្សសាមញ្ញ ដាក់ខ្លួន ស្តាប់បង្គាប់ លើកលែងទោស និងមានសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ។

កម្មវិធីបំប៉នអប់រំជំនឿនេះគឺមានការជួយសម្រួលពីលោកបូជាចារ្យទទួលបន្ទុកក្នុងតំបន់កំពង់ធំ ដូនជីកាតូលិក ២នាក់ ក្រុមដូនជីកាតូលិកមកពីប្រទេសថៃ៤នាក់ និងគ្រូអប់រំជំនឿមកពីព្រះសហគមន៍ផ្សេងៗជាច្រើននាក់ផងដែរ៕ *ដោយ រឿន ស្រីម៉ាច*



# សន្និបាតកុមារនៅប៊ូស្រាស្តីអំពី "ការស្តាប់បង្គាប់"

ពាក្យថា "ស្តាប់បង្គាប់"បើនិយាយចំពោះកុមារតូចៗគឺអាចឲ្យពួកគេយល់ច្រឡំអំពីអត្ថន័យ ព្រោះគេអាចនឹងប្រព្រឹត្តអំពើទុច្ចរិត ឬអំពើសុចរិតអាស្រ័យទៅលើការពន្យល់ និងណែនាំពីសំណាក់មនុស្សចាស់ទុំដែលនៅជុំវិញខ្លួនរបស់ពួកគេ។

ដើម្បីបញ្ជ្រាបអំពីបញ្ហានេះព្រះវិហារព្រះយេស៊ូប្រសូតជាមនុស្សនៅប៊ូស្រាដែលស្ថិតនៅក្នុងភូមិឡាំម៉េះ ឃុំប៊ូស្រា ស្រុកពេជ្រដា ខេត្តមណ្ឌលគិរីបានរៀបចំកម្មវិធីសន្និបាតសម្រាប់កុមារកម្រិតបឋមសិក្សា។ កម្មវិធីនេះមានកុមារចូលរួម ប្រមាណជា៦០នាក់ មកពីព្រះសហគមន៍កាតូលិកចំនួនបីកន្លែងគឺ ព្រះសហគមន៍កាតូលិកកែវស៊ីមា ដាក់ដាំ និងព្រះសហគមន៍កាតូលិកប៊ូស្រា កាលពីថ្ងៃទី១៩ ដល់ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨។

លោក ហ្វ្រង់ស្វ័រ ហេមេល្យដាល ជាបូជាចារ្យទទួលខុសត្រូវព្រះហគមន៍កាតូលិកតំបន់មណ្ឌលគិរីបានឲ្យដឹងថា៖ ទិសដៅសំខាន់ក្នុងកម្មវិធីសន្និបាតនេះ គឺដើម្បីតម្រង់ទិសឲ្យកុមារតូចៗនេះមានការរិះគិតឲ្យបានត្រឹមត្រូវនៅពេលដែលមាននរណាម្នាក់បញ្ជា ឬប្រាប់ឲ្យគេធ្វើអ្វីមួយ។ លោកបូជាចារ្យរូបនេះបានបន្ថែមទៀតថា៖ កុមារមានភាពស្មោះត្រង់គឺប្រៀបដូចជាក្រដាសស ហេតុនេះប្រសិនបើយើងជាមនុស្សធំបង្ហាញអ្វី ឬប្រាប់អ្វីដល់ពួកគេនឹងស្តាប់តាមដោយមិនវិនិច្ឆ័យថាល្អ ឬអាក្រក់នោះទេ។ លោក ហ្វ្រង់ស្វ័រក៏បានលើកឧទាហរណ៍យ៉ាងសាមញ្ញថា "ការបញ្ជាឲ្យក្មេងទៅសុំទាន ឬទៅលួចរបស់នរណាម្នាក់ គឺផ្ទុយពីការបញ្ជា ឬប្រាប់ឲ្យខិតខំរៀនសូត្រ និងធ្វើជាកូនល្អ"។



កម្មវិធីសន្និបាតនេះ មានកម្មវិធីជាច្រើនដូចជា ការលេងល្បែងកម្សាន្ត ការរិះគិតអំពីព្រះបន្ទូល ការស្តាប់រឿងនិទានអំពីព្រះយេស៊ូ ការមើលរឿងសន្តនិងសន្តីណែនាំអំពីការស្តាប់បង្គាប់ និងការទៅកម្សាន្តនៅទឹកជ្រោះជាក្រុមជាដើម។

លោក ហ្វ្រង់ស្វ័របានបន្តថា៖ ដើម្បីជាអំណះអំណាងលោកបានលើកយករឿងព្រះយេស៊ូអធិដ្ឋាន នៅក្នុងសួនច្បារកេតសេម៉ានី និងរឿងព្រះនាងម៉ារីជាមាតាព្រះយេស៊ូមកពន្យល់ដល់កុមារទាំងនោះស្តីពីការស្តាប់បង្គាប់។ លើសពីនោះទៅទៀតលោកក៏បានលើកយករឿងរ៉ាវដែលមិនល្អមួយចំនួននៅក្នុងសង្គមដូចជាការប្រើប្រាស់គ្រឿងញៀន ការបញ្ឈប់កុមារពីការសិក្សាដើម្បីទៅរកលុយ និងការលួចប្លន់គេជាដើម។ លោកបន្ថែមថា ការលើកយករឿងទាំងអស់នេះមកពន្យល់ គឺគ្រាន់តែចង់ឲ្យក្មេងៗចេះគិតពិចារណាឲ្យបានត្រឹមត្រូវ នៅពេលដែលមាននរណាម្នាក់ប្រាប់គេឲ្យធ្វើអ្វីមួយ និងគ្រប់កាយវិការទាំងអស់ ដូចជាការលួងលោម បញ្ចុះបញ្ចូល ឬការស្តីបន្ទោសផងដែរ។

អ្នករៀបចំកម្មវិធីរូបនេះមានការសង្ឃឹមថា បន្ទាប់ពីក្មេងៗទទួលការអប់រំអំពីការស្តាប់បង្គាប់រួចពួកគេចេះគិត និងយល់ច្បាស់អំពីអ្វីដែលល្អ និងអ្វីដែលអាក្រក់ អ្វីដែលគួរធ្វើ និងអ្វីដែលមិនគួរធ្វើ។ ចំពោះព្រះសហគមន៍កាតូលិកនឹងព្យាយាមណែនាំទាំងអំពីជំនឿ និងអំពីជីវិតក្នុងសង្គមខាងក្រៅឲ្យកាន់តែច្រើនតាមតែអាចធ្វើបាន។ លោកបូជាចារ្យក៏សូមឲ្យអាណាព្យាបាលទាំងអស់ព្យាយាមណែនាំ និងជំរុញកូនៗឲ្យមើលឃើញអំពីភាពស្មោះត្រង់ និងអំពើល្អ ដើម្បីឲ្យគេក្លាយជាក្មេងល្អ កូនល្អ ក្លាយជាយុវជនល្អ ពលរដ្ឋល្អ និងជាគ្រីស្តបរិស័ទល្អទាំងនៅក្នុងសង្គម និងព្រះសហគមន៍នៅថ្ងៃអនាគត។

សព្វថ្ងៃព្រះសហគមន៍ប៊ូស្រាមានគ្រីស្តបរិស័ទប្រមាណជា៩០នាក់ ដែលជ្រមុជទឹករួចហើយ មានកុមារ យុវជន ព្រមទាំងមនុស្សពេញវ័យមកទទួលការរៀនអប់រំជំនឿចំនួនប្រមាណជា៨០នាក់៕

*ដោយ រឿន ស្រីម៉ាច*

# កញ្ញា ណាន ស្រីនាង ៖ការអធិដ្ឋានគឺជាពេលវេលាសន្ទនាផ្ទាល់ជាមួយព្រះជាម្ចាស់



កញ្ញា ណាន ស្រីនាង

តាមរយៈសក្ខីភាពនៃជំនឿរបស់គ្រីស្តបរិស័ទម្នាក់ៗគឺសុទ្ធតែមានបទពិសោធ និងទស្សនៈខុសគ្នាៗតែអ្វី ដែលដូចគ្នានោះ គឺការមានជំនឿទៅលើព្រះគ្រីស្តតែមួយ។

យ៉ាងណាមិញកញ្ញា ណាន ស្រីនាង មានវ័យ៣០ឆ្នាំ ជាគ្រីស្តបរិស័ទមកពីព្រះសហគមន៍កាតូលិកកោះរការ បានឲ្យដឹងថា ៖ រាល់ពេលដែលនាងអធិដ្ឋាន គឺជាពេលវេលាមួយយ៉ាងពិសេស ហាក់បីដូចជាខ្លួនកំពង់ជួប និងសន្ទនាជាមួយព្រះជាម្ចាស់ផ្ទាល់។

ស្រីនាង ជាយុវនារីដែលមានស្រុកកំណើតនៅក្នុងភូមិកោះរការក្រៅ ឃុំកោះរការ ស្រុកកំពង់សៀម ខេត្តកំពង់ចាម នាងជាកូនទីពីរក្នុងចំណោមបងប្អូន៤នាក់ ក្នុងគ្រួសារជាពុទ្ធបរិស័ទ។

កំពុងអង្គុយផ្តល់សក្ខីភាពនៅក្នុងបន្ទប់តូចមួយ ដោយទឹកមុខញញឹមរួសរាយ កញ្ញា ស្រីនាងបានរំលឹកពីអតីតកាលថា៖ នៅក្នុងកំឡុងឆ្នាំ១៩៩៩ ស្រីនាង បានស្គាល់ព្រះសហគមន៍ តាមរយៈសកម្មភាពតូចៗរបស់គ្រីស្តបរិស័ទដែលជាអ្នកជិតខាងខ្លួន។ កាលនោះមានគ្រូអប់រំជំនឿ ឬបងស្រី ដែលតែងតែជួបជុំគ្នានៅផ្ទះគ្រីស្តបរិស័ទ ដោយសារនៅកោះរការមិនទាន់មានព្រះវិហារនៅឡើយ។

ស្រីនាងបន្តថា នាងចូលចិត្តទៅអង្គុយមើលគេ ហើយបងស្រីចែកស្ករគ្រាប់ឲ្យញ៉ាំ។ ហើយក្រោយៗមកទៀត មានកម្មវិធីហាត់របាំ កម្មវិធីអនាម័យក្មេងៗ ស្តាប់រឿងនិទាន និងលេងល្បែងផ្សេងៗ។ល។

ដំបូងនាងទៅជាមួយគេ គ្រាន់តែដើម្បីសប្បាយ បានញ៉ាំ ដូចក្មេងៗដ៏ទៃទៀតដែរ។ តែបន្តិចម្តងៗនាងមានអារម្មណ៍ថា ហាក់ដូចជា ព្រះសូសៀងរបស់ព្រះជាម្ចាស់លាន់ឮឡើងហើយជំរុញចិត្តខ្លួនឲ្យកាន់តែចង់ឈ្វេងយល់អំពីព្រះសហគមន៍កាតូលិកធ្វើថែមទៀត។

យុវនារីសម្បុរស្រអែមសក់រួញប្រះស្មារូបនេះបានឲ្យដឹងទៀតថា ៖ កញ្ញាមានម្តាយឪពុកជាកសិករ និងជាពុទ្ធបរិស័ទ។ ហើយអ្វីដែលជារនាំងនោះ គឺលោកទាំងពីរមិនអនុញ្ញាតឲ្យនាងទៅទទួលការអប់រំជំនឿក៏ដូចជាសកម្មភាពផ្សេងៗទៀតក្នុងព្រះវិហារឡើយ។

ដោយក្តីស្រឡាញ់ និងចង់ក្លាយជាគ្រីស្តបរិស័ទស្រីនាងបានសុំទៅឪពុកម្តាយ ដោយលើកហេតុផលផ្សេងៗតាមការយល់ឃើញរបស់ខ្លួន។ ក្នុងពេលវេលានោះ ស្រីនាងប្រាប់ថា នាងបេះអធិដ្ឋានដោយមិនដឹងខ្លួន គឺនាងសុំព្រះជាម្ចាស់ឲ្យបើកចិត្តឪពុកម្តាយដើម្បីយល់ព្រមតាមការស្នើរសុំរបស់ខ្លួន។ ដោយសេចក្តីប្រណីសន្តោសរបស់ព្រះជាម្ចាស់នាងបានទទួលអប់រំជំនឿក្រោមការអនុញ្ញាតរបស់ឪពុកម្តាយ និងលោកបូជាចារ្យដែលមានបន្ទុកដឹកនាំព្រះសហគមន៍ផង។

និយាយបណ្តើរញញឹមបណ្តើរ កញ្ញា ណាន ស្រីនាង បានបន្ថែមថា នាងត្រូវរង់ចាំរយៈពេល៦ឆ្នាំ បន្ទាប់ពីការស្គាល់ព្រះសហគមន៍ និងទទួលអប់រំជំនឿគឺនាងបានទទួលអគ្គសញ្ញាជ្រមុជទឹកនៅក្នុងឆ្នាំ២០០៦ នៅព្រះវិហារកំពង់ចាមក្រុង។

ស្រីនាង បាបញ្ជាក់អំពីជំនឿរបស់ខ្លួនទៀតថា ៖ សាសនាទាំងអស់ គឺអប់រំមនុស្សទៅរកពន្លឺ ដោយស្វែងរកទិសដៅមួយឲ្យជីវិតទៅតាមមាគ៌ារបស់គេ។ ទាំងអ្នកប្រតិបត្តិសាសនា និងអ្នកដែលមិនជឿលើសាសនាណាមួយ ក៏ចេះប្រព្រឹត្តអំពើល្អសន្សំបុណ្យកុសល ទៅតាមការជឿ និងការគិតរបស់គេរៀងៗខ្លួន។

ស្រីនាងនិយាយដោយទឹកមុខពោរពេញដោយមោទនភាពថា៖ "ខ្ញុំសប្បាយចិត្តណាស់! ដែលព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំឲ្យស្គាល់ព្រះអង្គ។ តាមជំនឿរបស់ខ្ញុំ ខ្ញុំរស់នៅដោយសេចក្តីសង្ឃឹម ចិត្តខ្ញុំមានសេរីភាពមិនគិតអំពីបុណ្យបាបទាំងឡាយ"។

នាងលើកអំណះអំណាងថា៖ ព្រះគ្រីស្តផ្ទាល់ដែលជាបុត្រារបស់ព្រះជាម្ចាស់បានយាងមកសង្គ្រោះយើង ដោយបូជាព្រះជន្មព្រះអង្គដើម្បីសង្គ្រោះមនុស្សលោក ហើយព្រះអង្គទ្រង់មានព្រះជន្មរស់ឡើងវិញដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ"។

កញ្ញា ណាន ស្រីនាង ជាយុវនារីម្នាក់ក្នុងចំណោម ពីរនាក់ផ្សេងទៀត គឺមានលោក កាន់ប៊ុយ និងបងស្រី ស្រី សុខជាតិ ដែលបានទៅបំពេញទេវវិទ្យាអំពីព្រះសហគមន៍នៅប្រទេសបារាំង ពីឆ្នាំ២០១៣ ដល់២០១៨។

តាមរយៈបទពិសោធការសិក្សាអំពីព្រះសហគមន៍កាតូលិកជាច្រើនស្រីនាង លើកឡើងថា សាសនាកាតូលិក គឺបានសម្តែងធម៌មេត្តាករុណាជាច្រើនតាមរយៈសកម្មភាពផ្សេងៗក្នុងសង្គម និងព្រះសហគមន៍ តែយើងធ្វើមិនមែនយើងចង់សន្សំបុណ្យកុសល ឬរំពឹងចង់បានអ្វីពីមកវិញទេ គឺយើងធ្វើដោយសារយើងជឿព្រះយេស៊ូគ្រីស្ត គឺព្រះគ្រីស្តបង្ហាញយើងឲ្យស្គាល់ថា ជីវិតមនុស្សទាំងអស់មានតម្លៃណាស់ ហើយតម្លៃនោះគឺស្មើៗគ្នា។

សព្វថ្ងៃកញ្ញា ណានស្រីនាងកំពង់បម្រើការងារនៅមណ្ឌលអប់រំជំនឿនៃព្រះសហគមន៍កាតូលិកកម្ពុជា និងជាជំនួយការនៅមណ្ឌលនិស្សិតកាតូលិកកម្ពុជាផងដែរ។ ស្រីនាងបានប្រាប់អំពីរបៀបដែលនាងតែងតែធ្វើទំនាក់ទំនងជាមួយព្រះជាម្ចាស់គឺការអានព្រះគម្ពីការអធិដ្ឋាន។ នាងថា តាមរយៈការងារ ខ្ញុំមានឱកាសបើកគម្ពីរអានរិះគិត។ មានថ្ងៃខ្លះព្រះបន្ទូលបានលើកទឹកចិត្តខ្ញុំ ថ្ងៃខ្លះខ្ញុំអធិដ្ឋាន ហើយពេលខ្លះខ្ញុំក៏ខានដែរ។ ពេលខ្លះទៀតជាមួយអ្នករួមការងារជាមួយគ្នា យើងបានចែករំលែកគ្នាអំពីជំនឿ យើងរិះគិតរួមគ្នា។ ប៉ុន្តែក្រៅពីសកម្មភាពទាំងនេះ គឺនាងមិនដែលភ្លេចទៅព្រះវិហារនៅថ្ងៃអាទិត្យដើម្បីចូលរួមថ្វាយអភិបូជា។ នាងថា "ការចូលរួមអភិបូជាបានជួយឲ្យខ្ញុំមានអារម្មណ៍ថាកក់ក្តៅព្រោះមានវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងជីវិតខ្ញុំជានិច្ច និងរក្សាជំនឿខ្ញុំមិនឲ្យភ្លេចព្រះជាម្ចាស់"។ ស្រីនាងបានបន្ថែមថា ៖ អ្វីដែលធ្វើឲ្យនាងរឹតតែសប្បាយចិត្តខ្លាំងនោះ គឺព្រះជាម្ចាស់បានត្រាស់ហៅឲ្យក្រុមគ្រួសារដែលមានម្តាយឪពុក និងប្អូន ប្រុសប្អូនស្រីរបស់ខ្លួនបានក្លាយជាគ្រីស្តបរិស័ទជាបន្តបន្ទាប់។

យុវនារីមកពីភូមិភាគកំពង់ចាមរូបនេះមានសកម្មភាពផ្សេងៗជាច្រើនក្នុងព្រះសហគមន៍ដូចជាអប់រំជំនឿតាមព្រះសហគមន៍ផ្សេងៗក្នុងភូមិភាគកំពង់ចាម និងភ្នំពេញ ចូលរួមសកម្មភាពជាមួយយុវជន និងកុមារ រៀបចំកម្មវិធីនានាក្នុងព្រះវិហារជាដើម។

ស្រីនាងបានមើលឃើញកម្មភាពព្រះសហគមន៍នៅប្រទេសកម្ពុជាដោយលើកឡើងថា "ព្រះសហគន៍ខ្មែរយើងកំពុងឈានទៅមុខពីមួយជំហានទៅមួយជំហាន ព្រោះព្រះជាសគមន៍កម្ពុជានៅសភាពក្មេងខ្ចីនៅឡើយ។ យើងត្រូវការធនធានជាច្រើនទៀតសម្រាប់ដឹកនាំព្រះសហគមន៍។ ព្រះសហគមន៍យើងមានយុវជនយុវនារីជាច្រើន ខ្ញុំមានក្តីសង្ឃឹមលើពួកគេ។ ខ្ញុំសង្ឃឹមថា ព្រះសហគមន៍ នឹងផ្តល់ឱកាសឲ្យកាន់តែច្រើនទៀត ឲ្យយុវជនយុវនារី ទៅសិក្សាស្វែងយល់អំពីឫសគល់នៃជំនឿ ដើម្បីពង្រឹងសមត្ថភាពពួកគេបន្ថែម ដើម្បីឲ្យគេអាចបម្រើព្រះសហគមន៍ឲ្យរីកចម្រើនទៅមុខបាន"។

កញ្ញាស្រីនាងបានឲ្យដឹងបន្តថា ជាទូទៅយើងម្នាក់ៗតែងតែភ្លេចព្រះជាម្ចាស់នៅពេលដែលយើងសប្បាយតែយើងតែងតែនឹកឃើញព្រះអង្គនៅពេលដែលយើងមានទុក្ខកង្វល់។ ហេតុនេះនាងសុំឲ្យគ្រីស្តបរិស័ទទាំងអស់កុំភ្លេចព្រះជាម្ចាស់បើទោះបីជាមានរឿងអ្វីកើតឡើងក៏ដោយ៕

*ដោយ ទឿន ស្រីម៉ាច*

# កិច្ចប្រជុំសភាលោកអភិបាលឡាវ-កម្ពុជា




ថតដោយ: សុវណ្ណភូមិ

ក្រុមសភាលោកអភិបាលនៃព្រះសហគមន៍កាតូលិក ឡាវ កម្ពុជា បានជួនគ្នាកិច្ចប្រជុំប្រចាំឆ្នាំដែលប្រព្រឹត្តទៅពីថ្ងៃទី១៧ ដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ នៅព្រះសហគមន៍ព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ (ពេទ្យឃាយជី) ខេត្តបាត់ដំបង។

ក្រុមលោកអភិបាលព្រះសហគមន៍កាតូលិកឡាវ-កម្ពុជាទាំងប្រាំពីររូប បានប្រជុំពិភាក្សា ផ្លាស់ប្តូរបទពិសោធ និងស្ថានភាពនៃការប្រកាសដំណឹងល្អនៅក្នុងប្រទេសទាំងពីរ ដើម្បីលើកទឹកចិត្តគ្នាទៅវិញទៅមក និងបង្កើនភាពរឹងមាំទំនាក់ទំនង មិត្តភាពរវាងព្រះសហគមន៍កាតូលិកទាំងពីរប្រទេស។

បន្ទាប់ពីប្រជុំជាងមួយថ្ងៃកន្លះរួចហើយ ក្រុមលោកអភិបាលទាំងអស់ក៏បានធ្វើទស្សនកិច្ចកន្លែងមួយចំនួន ដែលជាសកម្មភាពរបស់ព្រះសហគមន៍នៅក្នុងខេត្តបាត់ដំបង មានអង្គការករុណាបាត់ដំបង រោងចក្រតម្បាញនៃព្រះសហគមន៍តាហែន កម្មវិធីសហគ្រិនភាពសង្គមរបស់ព្រះសហគមន៍ភូមិភាគបាត់ដំបងជាដើម។

ក្រោយពីបញ្ចប់ដំណើរទស្សនកិច្ចព្រះសហគមន៍ព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ បានរៀបចំពិធីអរព្រះគុណព្រះជាម្ចាស់ ជាមួយក្រុមលោកអភិបាលឡាវ-កម្ពុជា កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨។

ដើម្បីបិទកិច្ចប្រជុំសភាលោកអភិបាលព្រះសហគមន៍កាតូលិកឡាវ-កម្ពុជា នាព្រឹកថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ ក្រុមលោកអភិបាលឡាវ-កម្ពុជាបានធ្វើដំណើរទៅថ្វាយអភិបូជា អរព្រះគុណព្រះជាម្ចាស់ នៅព្រះវិហារសន្តីតេរេសា នៃព្រះសហគមន៍កាតូលិកចំណោម ជាព្រះសហគមន៍កាតូលិកដ៏ចំណាស់មួយ ដែលបានបង្កើតឡើងតាំងពីឆ្នាំ ១៩៣៣ ដោយលោកបូជាចារ្យ អ័រម៉ង់ ដែលស្ថិតនៅក្នុងស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យផងដែរ។

បន្ទាប់ពីអង្គប្រជុំបានបញ្ចប់ ក្រុមលោកអភិបាលឡាវ ដឹកនាំដោយលោកគាឌីណាស់ លូវីស ម៉ារីលីង បានធ្វើទស្សនកិច្ចនៅតាមកន្លែងមួយចំនួន ដែលជាមណ្ឌលសកម្មភាពរបស់អង្គការការីតាស់កម្ពុជា នៅក្នុងខេត្តបាត់ដំបង៕

*ដោយ សុវណ្ណភូមិ*

# ជនក្រីក្រ១២៥គ្រួសារទទួលអំណោយពីព្រះវិហារសន្តយ៉ូសែប



ថតដោយ: លីហៀង

ជនក្រីក្រចំនួន១២៥គ្រួសារ ដែលរស់នៅក្នុងទីក្រុងភ្នំពេញបានទទួលសម្ភារជាគ្រឿងបរិភោគពីព្រះសហគមន៍កាតូលិក ព្រះវិហារសន្តយ៉ូសែប(ផ្សារតូច) កាលពីថ្ងៃទី៣ តុលា ២០១៨ ក្រោមការដឹកនាំដោយលោកបូជាចារ្យ ប៉ូល រឿង ផ័ត្រសីរី ដែលទទួលបន្ទុក មណ្ឌលសកម្មភាពព្រះសហគមន៍កាតូលិកភ្នំពេញខាងជើង រួមជាមួយគណៈកម្មការព្រះសហគមន៍។

តាមប្រសាសន៍លោកបូជាចារ្យ ផ័ត្រសីរី បានឲ្យដឹងថា ជាជាធម្មតាព្រះសហគមន៍ផ្សារតូច តែងតែចែករំលែកនូវអំណោរសប្បាយ សេចក្តីសង្ឃឹម ដែលមកពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ទៅដល់បងប្អូនដែលខ្វះខាត។ លោកបន្តថា ជាពិសេសក្នុងឱកាសបុណ្យប្រពៃណីជាតិខ្មែរ ដូចជាបុណ្យចូលឆ្នាំ បុណ្យភ្ជុំ ប្រជាពលរដ្ឋខ្មែរនាំគ្នាធ្វើបុណ្យឧទ្ទិសកុសលដោយដាក់ទានដល់អ្នកខ្វះខាតដើម្បីកុំឲ្យកើតជាប្រេត។ លោកបញ្ជាក់ថា ផ្ទុយមកវិញ គ្រីស្តបរិស័ទកាតូលិក យើងរួមគ្នាជាព្រះសហគមន៍ បានយកកិច្ចការនៃធម៌មេត្តាករុណា ដែលជាសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលព្រះយេស៊ូបានបង្រៀន និងជាឱកាសដើម្បីប្រកាសដំណឹងល្អ និងធ្វើជាសាក្សីនៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ផងដែរ។

លោកផ័ត្រសីរី បន្ថែមថា កិច្ចការចែករំលែកក្នុងឱកាសពិធីបុណ្យប្រពៃណីជាតិនេះ ជាទំនៀមទម្លាប់របស់ព្រះសហគមន៍ដែលមានតាំងពីឆ្នាំ១៩៩៣មកម្ល៉េះ គឺចាប់តាំងពីចាប់ផ្តើមព្រះសហគមន៍ក្រោយសម័យប៉ុលពត។ បរិយាកាសពីមុន និងពេលនេះខុសគ្នាដោយមានបងប្អូនខ្លះមានជីវភាពគ្រាន់បើជាងមុន ប៉ុន្តែនៅតែមានអ្នកខ្វះខាតដដែល។ លោកបានសង្កត់ធ្ងន់ដោយលើកយកអត្ថបទព្រះគម្ពីរ "ប្រសិនបើគ្មានការប្រព្រឹត្តអំពើល្អទេ ជំនឿនោះស្លាប់តែម្តង"(យក២,១៤-២៦)។

ជនក្រីក្រដែលមកទទួលអំណោយថ្ងៃនេះមានចំនួន១២០គ្រួសារ និង៥គ្រួសារទៀតដែលអវត្តមានព្រះសហគមន៍នៅតែរក្សាទុកប្រគល់ជូនពួកគាត់តាមក្រោយ។ ជនទាំងនោះបានទទួលគ្រឿងបរិភោគដូចជា អង្ករ ទឹកត្រី មី។ល។

រីឯថវិកាសម្រាប់ធ្វើកិច្ចការទាំងនេះបានមកពីការចូលរួមរបស់គ្រីស្តបរិស័ទទូទៅនៃព្រះវិហារសន្តយ៉ូសែប៕

*ដោយ ដាលីស*

# បញ្ជីរាយនាម លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ




ដំណឹងល្អបានមកដល់ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាតាំងពីឆ្នាំ១៥៥៥ មកម្ល៉េះ ដោយបព្វជិតកាតូលិកនៃក្រុមដូមីនិកូ ជាតិព័រទុយហ្គាល់ នាម ហ្គាស្ប៉ាដាគ្រូសលោកស្នាក់នៅក្នុងព្រះបរមរាជវាំង រាជធានីលង្វែក។ នៅឆ្នាំ១៥៧៤ មានបព្វជិតជាព័រទុយហ្គាល់ ម្នាក់ទៀតបានមកដល់លោកស្នាក់នៅកម្ពុជា២០ឆ្នាំ លោកបានកសាងព្រះវិហារមុនគេ។

ជាបន្តបន្ទាប់ព្រះសហគមន៍កាតូលិកបានរីកចម្រើនបន្តិចម្តងៗរហូតមក និងបានចូលរួមក្នុងប្រវត្តិសាស្ត្រកម្ពុជាយ៉ាងជិតស្និទ្ធ ទាំងអំណរសប្បាយ ទាំងក្នុងគ្រាទុក្ខលំបាក ភ្លើងសង្គ្រាម ភាពវឹកវរក្នុងស្រុក...។ល។ ជាពិសេសក្នុងទសវត្សរ៍ចុងក្រោយនេះ គឺ១៩៧០ដល់ ១៩៧៩ អ្វីត្រូវបំផ្លាញទាំងស្រុង បព្វជិតបព្វជិតា ត្រូវបានស្លាប់ និងសម្លាប់ចោល គ្រីស្តបរិស័ទបែកខ្ញែកខ្ចាត់ខ្ចាយ ខ្លះក៏ត្រូវបានគេសម្លាប់ចោលផងដែរព្រោះជំនឿ។ សំណង់អាគារព្រះវិហារទាំងឡាយត្រូវបំផ្លាញខ្ទេចគ្មានសល់។ ព្រះសហគមន៍រស់ឡើងវិញនៅពេលប្រទេសមានសន្តិភាពពេញលេញ ក្នុងទសវត្សរ៍ចុងក្រោយនេះ។

ទោះបីជាយ៉ាងនេះក្តី ព្រះសហគមន៍កាតូលិក នៅកម្ពុជា ឬភូមិភាគភ្នំពេញ មានអ្នកដឹកនាំ និងណែនាំ គឺលោកអភិបាលព្រះសហគមន៍កាតូលិកចាប់តាំងពីឆ្នាំ១៦៥៨មក។ តើមានលោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញមាននាមអ្វីខ្លះ?

លោកឡាំប៊ែរត៍ ដឺឡាម៉ុត៍ ពីឆ្នាំ១៦៥៨ ដល់ឆ្នាំ ១៦៧៩។ លោក ម៉ាហូត ពីឆ្នាំ ១៦៧៩ ដល់ឆ្នាំ ១៦៨២។ លោកឡា ណូ ពីឆ្នាំ ១៦៨២ ដល់ឆ្នាំ ១៦៩១។ លោក ប៉េរែស ពីឆ្នាំ ១៦៩១ ដល់ឆ្នាំ ១៧២៨។ លោក ឌឺ អាឡិចហ្សង់ឌ្រីស ពីឆ្នាំ ១៧២៨ ដល់ឆ្នាំ១៧៣៨។ លោកឡឺ ប្រែហ្វប ពីឆ្នាំ ១៧៤១ ដល់ឆ្នាំ១៧៦០។ លោកពីគែល ពីឆ្នាំ១៧៦០ ដល់ឆ្នាំ១៧៧១។ លោក ពីញ៉ូ ដឺ បេហែន ពីឆ្នាំ១៧៧១ ដល់ឆ្នាំ ១៧៩៩។ លោកឡាប័រទ្បេត៍ ពីឆ្នាំ ១៧៩៩ ដល់ឆ្នាំ១៨២៣។ លោក តាបេរដ៍ ពីឆ្នាំ ១៨២៧ ដល់ឆ្នាំ១៨៤០។ លោក ស្តេផាន គូរណេូ បីឆ្នាំ១៨៤០ ដល់ឆ្នាំ១៨៤៤។ លោកដូមីនីក ឡឺប្រែហ្វប ពីឆ្នាំ១៨៤៤ ដល់ឆ្នាំ១៨៥០។ លោក យ៉ូហាន ក្លូដមីស្ស ពីឆ្នាំ១៨៥០ ដល់ ១៨៦៩។ ជាអភិបាលកាតូលិកមួយរូបដែលបានជួយព្រះបាទអង្គឌួង ឲ្យមានទំនាក់ទំនងជាមួយបារាំង។

ពីឆ្នាំ១៨៦៩ ដល់ឆ្នាំ១៨៨២ រយៈពេល ១៣ឆ្នាំ ព្រះសហគមន៍កាតូលិកភ្នំពេញគ្មានអភិបាលទេ គឺមានលោកបូជាចារ្យ អូស៊ូលៃ និងលោកបូជាចារ្យ គ័រឌីយេ បំពេញមុខងារជំនួស។

លោក គ័រឌីយេ ពីឆ្នាំ១៨៨២ ដល់ឆ្នាំ ១៨៩៥។ លោក យ៉ូហាន បាទីស្ទក្រូចចស៍ ពីឆ្នាំ១៨៩៦ ដល់ឆ្នាំ១៩០២។ លោក យ៉ូហាន ក្លូដប៊ូស៊ូ ពីឆ្នាំ១៩០២ ដល់ឆ្នាំ ១៩២៨។ លោក វ៉ាឡង់ទីន ហែរកុត ពីឆ្នាំ១៩២៨ ដល់ឆ្នាំ១៩៣៦។ លោក យ៉ូហាន បាទីស្ទ សាបាលីយេ ពីឆ្នាំ១៩៣៧ ដល់ឆ្នាំ១៩៥៥។ លោក ហ្គូស្តាវ៉ រ៉ាបាឡាំង ពីឆ្នាំ១៩៥៦ ដល់ឆ្នាំ១៩៦២។ លោក អ៊ីវ៉ រ៉ាមូស ពីឆ្នាំ១៩៦៣ ដល់ឆ្នាំ ១៩៧៥។ លោក យ៉ូសែប ឆ្មារ សាឡាស់ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ លោកទទួលមរណភាពក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(ប៉ុល ពត) ដោយការស្រេកឃ្លាន និងធ្វើការជាទម្ងន់។ លោក អ៊ីវ៉ រ៉ាមូស ឆ្នាំ១៩៩២ ដល់២០០១។ លោកអេមីល ដេតម្ប ពីឆ្នាំ២០០១ ដល់ឆ្នាំ២០១០។ លោក អូលីវីយេ ឆ្មឹតអីស្ល៊ែរ ២០១០ រហូតមកដល់បច្ចុប្បន្ន។

នៅឆ្នាំ១៩៦៨ សន្តអសនៈ បានបែងចែកព្រះសហគមន៍កាតូលិកភូមិភ្នំពេញជាបី មានដូចជា៖ ភូមិភាគភ្នំពេញ គ្របដណ្តប់លើ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់ស្ពឺ ខេត្តកែប ខេត្តព្រះសីហនុ និងខេត្តកោះកុង។ ភូមិភាគបាត់ដំបងគ្របដណ្តប់ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តមានជ័យ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តពោធិសាត់។ ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម គ្របដណ្តប់ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តមណ្ឌលគិរី ខេត្តរតនៈគិរី ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ។ សព្វថ្ងៃមានលោក អូលីវីយេ ឆ្មឹតអីស្ល៊ែរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ លោក អែនរីកេ ហ្វីការេដូជាអភិបាលភូមិភាគបាត់ដំបង និងលោក អន់តូនី ស៊ូសៃរាជ្យ ជាអភិបាលភូមិភាគកំពង់ចាម៕

# យុវជនឈ្វេងយល់ ពីតួនាទីគ្រួសារជាគ្រឹះនៃព្រះសហគមន៍ និងសង្គម




ថតដោយ : សុវណ្ណភូមិ

គ្រួសារជាគ្រឹះនៃព្រះសហគមន៍ និងសង្គម គឺជាប្រធានបទនៃមហាសន្និបាតយុវជនកាតូលិកទូទាំងប្រទេសកម្ពុជា ដែលបានធ្វើនៅព្រះសហគមន៍ព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ (ពេទ្យយាយជី) ខេត្តបាត់ដំបង ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៨។

ក្នុងមហាសន្និបាតនេះមានការចូលរួមពីតំណាងយុវជនយុវនារីទាំងបីភូមិភាគ ចំនួនប្រមាណជាង៤០០នាក់ និងមានវត្តមាន លោកអភិបាល លោកបូជាចារ្យ បងប្រុស និងបងស្រីផងដែរ។

អង្គសន្និបាតមានកម្មវិធីសំខាន់ៗដូចជា ទទួលការអប់រំពីវាគ្មិនមកពីភូមិភាគទាំងបី ការរិះគិតជាក្រុម ចូលរួមថ្វាយអភិបូជា ការអធិដ្ឋាន និងចុងក្រោយការរៀបចំផែនការអនុវត្តតាមភូមិភាគនីមួយដាក់ស្តែង។

ក្នុងធម្មទេសនានៃអភិបូជាបើកមហាសន្និបាត លោកអភិបាល អេនរីគេ ហ្វីការេដូ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង និងក្នុងនាមជាម្ចាស់ផ្ទះ បានថ្លែងថា យើងមានប្រធានបទនៃអង្គសន្និបាត គឺ"ក្រុមគ្រួសារដែលជាគ្រឹះសម្រាប់ព្រះសហគមន៍និងសង្គម" ដូច្នេះក្រុមគ្រួសារនឹងជួយយើងកសាងព្រះសហគមន៍ និងសង្គមមួយដែលមានវត្តមានរបស់ព្រះជាម្ចាស់។ លោកអភិបាលក៏បានលើកយកបីចំណុច ដើម្បីឲ្យយុវជនយុវនារីរិះគិត គឺសូមយុវជនយកគំរូរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់យើង ដោយបង្ហាញសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់សម្រាប់មនុស្សទាំងអស់។ ម្យ៉ាងទៀត យុវជន ត្រូវតែអធិដ្ឋាន និងទូលអង្វរព្រះជាម្ចាស់ប្រទានសេចក្តីស្រឡាញ់ឲ្យយើងមានសេចក្តីស្រឡាញ់ដូចព្រះជាម្ចាស់។ ចុងក្រោយគឺសូមឲ្យយុវជនមានទំនាក់ទំនងល្អរវាងគ្នានឹងគ្នា ឲ្យមានចិត្តមេត្តាករុណា ដូចព្រះជាម្ចាស់មានព្រះហឫទ័យមេត្តាករុណា។

លោកបូជាចារ្យ អាដ្រៀយ៉ាន បេនីតេស ហ្វូស្តារ៉ូ ជាប្រធានគណកម្មការយុវជនអន្តរភូមិភាគ បានពន្យល់ពីប្រធានបទថា "ក្រុមគ្រួសារដែលជាគ្រឹះសម្រាប់ព្រះសហគមន៍និងសង្គម" វាមានលក្ខណៈជាមនុស្ស។ គ្រួសារជាកន្លែងដែលយើងទទួលការអប់រំ គ្រួសារជាគំរូដ៏តូចមួយនៃសង្គម។ គ្រួសារជាព្រះសហគមន៍ដ៏តូចក្នុងផ្ទះ។ លោកថា យើងត្រូវការទទួលការអប់រំ និងត្រៀមខ្លួនដើម្បីទទួលខុសត្រូវគ្រួសារមួយ។ លោកបន្តថា យុវជនយុវនារីនឹងបានរៀន និងទទួលពីប្រធានបទក្នុងអង្គសន្និបាតនេះគឺ ការអប់រំអំពីសេចក្តីស្រឡាញ់ ជីវិតជាគូស្រករ និងគ្រួសារថ្មី ការអប់រំរបស់ព្រះសហគមន៍តាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់។

លោកបូជាចារ្យ ផាន បូរី និងសហការីតំណាងឲ្យព្រះសហគមន៍ភូមិភាគកំពង់ចាម បានធ្វើបទបង្ហាញអំពីប្រធានបទអាពាហ៍ពិពាហ៍រៀបចំដោយឪពុកម្តាយ អាពាហ៍ពិពាហ៍ជ្រើសរើសដោយខ្លួនឯង និងគ្រួសារសន្តិភាព។ ក្នុងនោះដែរវាគ្មិនលោកផាន ប៉ូរ៉ា បានលើកឡើងពីអំពីការដោះស្រាយទំនាស់នៅក្នុងក្រុមគ្រួសារផងដែរ ដើម្បីកសាងគ្រួសារមួយប្រកបដោយសុភមង្គល។ នៅចុងបញ្ចប់នៃការធ្វើបទបង្ហាញ លោកបូជាចារ្យ ប៉ូល ឡាយ បានដាក់ចំណុចបីដល់អង្គសន្និបាត គឺទីមួយ តើគូស្រករត្រូវទទួលចំណុចល្អអ្វីខ្លះពីឪពុកម្តាយ? តើបងប្អូនបានត្រៀមខ្លួនអ្វីខ្លះពីឪពុកម្តាយ? ទីពីរ តើការជ្រើសរើសគូស្រករដោយខ្លួនឯងមានចំណុចល្អអ្វីខ្លះ? តើបងប្អូនបានត្រៀមអ្វីខ្លះសម្រាប់ខ្លួនឯង? ទីបី តើយុវជនយុវនារី បានត្រៀមធនធានអ្វីដើម្បីរៀបអាពាហ៍ពិពាហ៍?

លោក ឆេង ម៉ាប់ តំណាងឲ្យព្រះសហគមន៍ភូមិភាគបាត់ដំបង បានលើកយកប្រធានបទ អំពីសេចក្តីស្រឡាញ់ សេចក្តីស្នេហា មកពន្យល់ក្នុងមហាសន្និបាត។ លោកបានសង្កត់ធ្ងន់ថា សេចក្តីស្រឡាញ់មានប្រាំដំណាក់កាលគឺ ស្រឡាញ់ខ្លួនឯង ស្រឡាញ់គេដើម្បីខ្លួនឯង ស្រឡាញ់គេដើម្បីគេ ស្រឡាញ់គ្នាហើយចែករំលែកទៅអ្នកដទៃ និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ លោកក៏បានដាក់សំណួរពីរ ដើម្បីឲ្យអង្គសន្និបាតទាំងមូលរិះគិត គឺទីមួយ តើសេចក្តីស្រឡាញ់របស់បងប្អូនម្នាក់ៗស្ថិតក្នុងដំណាក់កាលមួយណាក្នុងដំណាក់កាលទាំងប្រាំ? ទីពីរ ដើម្បីពង្រីកសេចក្តីស្រឡាញ់របស់បងប្អូនឲ្យកាន់តែធំតើយើងគួរធ្វើអ្វីខ្លះ?

លោកអភិបាល អូលីវីយេ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានអប់រំអំពីប្រធានបទ គ្រួសារដ៏សុខសាន្ត។ លោកអភិបាល បានលើកយកចំណុចពីរសំខាន់ៗ គឺទីមួយគ្រួសារនៅក្នុងសង្គមបច្ចុប្បន្ន ដែលត្រូវគិតអំពីគំរូនៃក្រុមគ្រួសារ ភាពក្រីក្រ ពលករចំណាកស្រុក និងអាពាហ៍ពិពាហ៍អន្តរសាសនា។ ទីពីរ អំពីគ្រួសារដ៏វិសុទ្ធ ដែលបានបង្ហាញអំពីការស្រឡាញ់ និងការយកចិត្តទុកដាក់ធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ការគោរពតាមប្រពៃណី សេចក្តីស្រឡាញ់របស់ឪពុកម្តាយ និងការអប់រំណែនាំកូនដ៏ត្រឹមត្រូវ ដើម្បីឲ្យមានសេចក្តីសុខសាន្ត។ បន្ទាប់មកលោកអភិបាលក៏បានដាក់ទីពីរសំណួរ ដើម្បីឲ្យអង្គសន្និបាតទាំងមូលរិះគិត គឺទីមួយ តើបងប្អូនយល់ និងគិតយ៉ាងណាអំពីគ្រួសារនៅក្នុងសង្គមបច្ចុប្បន្ននេះ? ទីពីរ តើគ្រួសារដ៏សុខសាន្តគឺជាអ្វីសម្រាប់ខ្ញុំ?

ក្នុងធម្មទេសនានៃអភិបូជាបិទមហាសន្និបាត លោកអភិបាល អូលីវីយេ បានផ្តាំផ្ញើដល់យុវជនយុវនារីនិងគ្រីស្តបរិស័ទទាំងអស់ថា សូមយកចិត្តទុកដាក់ស្តាប់ព្រះសូរសៀងរបស់ព្រះជាម្ចាស់ ដែលមានសំឡេងស្រាលៗមកយើង។ ឲ្យយើងលះបង់ខ្លួនឯងចោល ហើយលីឈើឆ្កាងរបស់ខ្លួនដើរតាមព្រះយេស៊ូ ដោយសួរខ្លួនឯងថា តើព្រះយេស៊ូជានរណាសម្រាប់យើង? លោកអភិបាលក៏បានបន្តថា ឲ្យយើងបង្កើតមហាគ្រួសារនៃព្រះសហគមន៍កាតូលិកនៅកម្ពុជា ដែលពោរពេញដោយកម្លាំងដើម្បីបង្ហាញថា យើងជាគ្រីស្តបរិស័ទយើងមានសមត្ថភាពដោយសារព្រះយេស៊ូ ដើម្បីបង្កើតសង្គមថ្មី។

ថ្ងៃចុងក្រោយនៃអង្គសន្និបាត ក្រុមយុវជនតាមភូមិភាគនីមួយៗ បានរៀបចំផែនការសកម្មភាព អនុវត្តដាក់ស្តែងនៅតាមកន្លែងនៃព្រះសហគមន៍កាតូលិកភូមិភាគនីមួយ ស្របតាមស្មារតីនៃខ្លឹមសារអង្គសន្និបាត៕

*ដោយ សុវណ្ណភូមិ*

# ប្រជាពលរដ្ឋ៥៣២គ្រួសារ ក្នុងស្រុកពីរនៃខេត្តកណ្តាលទទួលអំណោយ ពីរអភិបាលព្រះសហគមន៍កាតូលិក




លោក អូលីវីយេ ដ្មីតអីស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានអញ្ជើញចែកសម្ភារ និងគ្រឿងបរិភោគ ដល់បងប្អូនដែលរងគ្រោះដោយទឹកជំនន់ នៅតាមដងទន្លេមេគង្គចំនួន៥៣២គ្រួសារ ដែលមកពីភូមិរោងចក្រ ភូមិសំរោងធំ ស្រុកកៀនស្វាយ ភូមិកំពង់ចម្លង និងភូមិព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្តាល នាថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៨។

ក្រុមគ្រួសារប្រជារងគ្រោះទាំងនោះ ទទួលបានសម្ភារ និងគ្រឿងបរិភោគ មានដូចជា៖ អង្ករ២៥គ.ក មី១កេស ទឹកស៊ីអ៊ីវ ទឹកត្រី ប្រេងឆា អំបិល ស្ករស ស្ករគ្រាប់ និងមុង១ ដែលបានមកពីការរួមសហការរវាងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ជាមួយនឹងអង្គការការីតាសកម្ពុជា។

ក្នុងឱកាសនោះលោក វីរជ័យ ជាបូជាចារ្យទទួលខុសត្រូវ ព្រះសហគមន៍មណ្ឌលសកម្មភាពមេគង្គ បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ លោកអភិបាល អូលីវីយេ និងនាយកប្រតិបត្តិអង្គការការីតាសកម្ពុជា ដែលបានអញ្ជើញមកសួរសុខទុក្ខ និងនាំយកសម្ភារប្រើប្រាស់ គ្រឿងបរិភោគ ចែកជូនបងប្អូនដែលរង-គ្រោះដោយទឹកជំនន់តាមដងទន្លេមេគង្គ ចំនួន៥៣២គ្រួសារនាពេលនេះ។

ក្នុងពេលសំណេះសំណាលជាមួយប្រជាពលរដ្ឋ លោកគីម រតនា នាយកប្រតិបត្តិអង្គការការីតាសកម្ពុជា បានបញ្ជាក់ថាអង្គការការីតាសកម្ពុជា ជាអង្គការមនុស្សធម៌នៃព្រះសហគមន៍កាតូលិកដែលមានបេសកកម្មបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដល់មនុស្សទាំងអស់ ជាពិសេសប្រជាជនក្រីក្រ ជនងាយរងគ្រោះ និងជនរងគ្រោះ ពីការរំលោភបំពាន និងគ្រោះធម្មជាតិ។ លោកបន្តថា អង្គការការីតាសមានសមាជិកចំនួន ១៦៨ប្រទេស លើពិភពលោក។ ចំពោះសម្ភារ ដែលយកមកប្រគល់ជូនបងប្អូននៅពេលនេះ គឺបានមកពីថវិកានៃការចូលរួមរបស់ប្រជា-ជនពីប្រទេសនានាលើសាកលលោក។ ចាប់តាំងពីមានទឹកជំនន់រហូតមកពេលនេះអង្គការការីតាសកម្ពុជាបាននាំយកសម្ភារជាជំនួយមនុស្សធម៌ ទៅប្រគល់ជូនជនរងគ្រោះដោយទឹកជំនន់ និងគ្រោះធម្មជាតិនានា បានចំនួនប្រមាណជិត ៥០០០គ្រួសារ។ លោកនាយកប្រតិបត្តិអង្គការការីតាសក៏មិនភ្លេចរំលឹកដាស់តឿនប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់ ឲ្យយកចិត្តទុកដាក់ថែរក្សាសុខភាព រស់នៅប្រកបដោយអនាម័យ និងចូលរួមថែរក្សាបរិស្ថាន។

នៅក្នុងឱកាសដ៏មានអត្ថន័យ លោកអភិបាល អូលីវីយេ បានបញ្ជាក់បន្ថែមអំពីអត្តសញ្ញាណរបស់អង្គការការីតាសជាអង្គ-ការនៃព្រះសហគមន៍កាតូលិក មានបេសក-កម្មជួយជនរងគ្រោះទាំងនៅកម្ពុជា និងនៅប្រទេសផ្សេងៗទៀត ជាក់ស្តែងថ្មីៗនេះពេលមានទឹកជំនន់ពីការបាក់ទំនប់វារីអគ្គីសនី នៅប្រទេសឡាវ អង្គការការីតាសកម្ពុជាក៏បានជួយជនរងគ្រោះនៅប្រទេសឡាវ ក៏ដូចនៅកម្ពុជាយើងដែរ។ លោកអភិបាលក៏បានបញ្ជាក់អំពីនិមិត្តសញ្ញារបស់អង្គការនេះ ដែលរូបសញ្ញាឈើឆ្កាងពណ៌ក្រហម និងពាក្យការីតាសជាភាសាបរទេស ដែលមានន័យខ្មែរថា ករុណា ជាសេចក្តីស្រឡាញ់ដែលមកព្រើពះជាម្ចាស់។ បងប្អូនជុំវិញពិភពលោកបានចូលរួមជាមួយគ្នាក្នុងសេចក្តីស្រឡាញ់នេះ។ ពេលយើងអង្គុយនៅទីនេះដូចអង្គុយជាមួយបងប្អូនទាំងនោះដែរ។ លោកក៏លើកទឹកចិត្តឲ្យបងប្អូនចេះចែករំលែក និងគិតគូរដល់អ្នកដទៃផង ពេលបងប្អូនបានទទួលច្រើនហើយនោះ។

លោកអភិបាលក៏បានជំរុញឲ្យបងប្អូនយកចិត្តទុកដាក់ថែរក្សាកូនៗកុំឲ្យមានជំងឺ ឬលង់ទឹកស្លាប់។ ជាពិសេសត្រូវជំរុញកូនៗឲ្យចុះឈ្មោះចូលរៀនឲ្យបានគ្រប់ៗគ្នា។ កុំឲ្យកូនឈប់រៀនដើម្បីរកលុយឡើយ។ លោកថាជាគ្រីស្តបរិស័ទ បើមិនឲ្យកូនៗបានរៀនសូត្រទេគឺ ជាអំពើបាប។

ព្រះសហគមន៍កាតូលិក នៅភូមិភាគភ្នំពេញ ក៏ដូចជាអង្គការការីតាស់កម្ពុជា បានយកចិត្តទុកខិតខំបំពេញបេសកកម្មរបស់ខ្លួន បម្រើប្រជាពលរដ្ឋកម្ពុជា ក្នុងវិស័យអប់រំ កិច្ចការមនុស្សធម៌ សុខាភិបាល កសិកម្ម អភិវឌ្ឍន៍ជនបទ ជួយជនពិការ ចាស់ជរា កុមារកំព្រាជាដើម។ ល។

# ពលរដ្ឋទាំង២០០គ្រួសារ ទទួលសម្ភារ គ្រឿងបរិភោគពីអង្គការការីតាសកម្ពុជា



លោកអន់តូនី ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគ កំពង់ចាមរួមជាមួយ លោកបូជាចារ្យ លោកនាយកប្រតិបត្តិអង្គការការីតាសកម្ពុជា បានអញ្ជើញ ទៅសួរសុខទុក្ខបងប្អូន និងបាននាំយកសម្ភារប្រើប្រាស់និងគ្រឿងបរិភោគ ទៅប្រគល់ជូនបងប្អូនរងគ្រោះដោយទឹកជំនន់នៅតាមវាលទំនាប នៃដងទន្លេមេគង្គក្រោម នៅភូមិកន្លើនិងកោះសំពៅក្នុងស្រុងពាមជរ ខេត្តព្រៃវែង នៅថ្ងៃទី៥ ខែតុលានេះ ដែលរងគ្រោះដោយទឹកជំនន់ ចំនួនជាង២០០ គ្រួសារ។

លោកឡាយ ប៉ូល បូជាចារ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិកតំបន់នេះ មានប្រសាសន៍ ថាបងប្អូនរស់នៅតំបន់នេះជាតំបន់ទំនាប ទឹកលិច ជារៀងរាល់រដូវវស្សា។ ជីវភាពរបស់ពលរដ្ឋក្នុងតំបន់នេះមានការលំបាក ទាំងការធ្វដំណើរ និងប្រកបរបរចិញ្ចឹមជីវិត។ នៅរដូវទឹកស្រកពលរដ្ឋទាំងនោះអាចប្រកបរបរ ធ្វើស្រែប្រាំង និងរកត្រីក្នុងរដូវបើកនេសាទ។

លោកបានផ្តួចផ្តើមគំនិតនាំយកសម្ភារមកប្រគល់ជូនបងប្អូនដើម្បីបានរួចមួយគ្រា ខណៈពេលដែលបងប្អូនរកអីមិនបាននាពេលនេះ។

សម្ភារទាំងនោះរួមមាន អង្ករ២៥ គីឡូក្រាម មី១កេះ ម្សៅសាប៊ូ សាប៊ូដុះខ្លួន ប្រេងឆា ស្ករស ទឹកដោះគោ ត្រីខ ថ្នាំដុសធ្មេញជាដើម ដែលបានមកពីអង្គការការីតាសកម្ពុជា រួមជាមួយលោកអភិបាលភូមិភាគបាត់ដំបង និងលោកបូជាចារ្យជាតិខ្មែរ។ ល។

ក្នុងឱកាសនោះលោកអន់តូនី បានមានប្រសាសន៍លើកទឹកចិត្តបងប្អូនទាំងអស់សូមឲ្យមានសេចក្តីសុខ និងមានការតស៊ូឆ្លងផុតនូវការលំបាកនានា៕

# ពលរដ្ឋខេត្តក្រចេះ និងស្ទឹងត្រែង ជាង១០០០ គ្រួសារ ទទួលជំនួយមនុស្សធម៌ពីការីតាស



អង្គការបរីសតាស់កម្ពុជា បានបន្តដំណើរទៅខេត្តស្ទឹងត្រែង និងក្រចេះ ដើម្បីនាំយកអំណោយមនុស្សធម៌សង្គ្រោះ បន្ទាន់ប្រគល់ជូនបងប្អូនប្រជាពលរដ្ឋ ដែលរងគ្រោះដោយសារទឹកជំនន់ ចំនួន៧៦០ គ្រួសារ ក្នុងខេត្តក្រចេះ និង ចំនួន ៦១៩ គ្រួសារក្នុងស្ទឹងត្រែង កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៨ ក្រោមអធិបតីភាពរបស់លោក ញឹម វណ្ណដា ទេសរដ្ឋមន្ត្រី និងជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

អង្គការការីតាស់កម្ពុជា ជាងអង្គការក្រៅរដ្ឋាភិបាល នៃព្រះសហកមន៍កាតូលិក ដែលបានបំពេញកិច្ចយ៉ាងសកម្មក្នុងការចូលរួមការអភិវឌ្ឍ និងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ រួមជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ចំពោះកិច្ចការសង្គ្រោះបន្ទាន់ជួយជនរងគ្រោះដោយទឹកជំនន់បានធ្វើការយ៉ាងជិតស្និតជាមួយគណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក៏ដូចជាកាកកាបាតក្រហមកម្ពុជា។

កាលពីម្សិលមិញអង្គការការីតាស់កម្ពុជា បាននាំយកជំនួយជាសម្ភារ និងគ្រឿងបរិភោគ ប្រគល់ជូនប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ក្នុងខេត្តត្បូងឃ្មុំ ចំនួន ១០២០គ្រួសារ ក្នុងនោះមានគ្រួសារខ្មែរឥស្លាម ចំនួនប្រមាណ ៥០០គ្រួសារ។

អង្គការការីតាស់កម្ពុជាក៏នឹងបន្តសកម្មភាពប្រគល់អំណោយមនុស្សធម៌ជូនប្រជាពលរដ្ឋរងគ្រោះដោយសារទឹកជំនន់ នៅខេត្តព្រៃវែង និងខេត្តកណ្តាលជាបន្តទៀត។

គ្រួសារនីមួយៗទទួលបានអង្ករចំនួន ២៥ គីឡូក្រាម មី ១កេស និងតង់ ១ ទំហំ ៤x ៥ ម៉ែត្រ៕



គ្រីស្តបរិស័ទកាតូលិកប្រារព្ធបុណ្យភ្ជុំ ឧទ្ទិស














ដល់វិញ្ញាណក្ខន្ធមរណៈបុគ្គលទាំងឡាយ











# សិក្ខាសាលាអំពីតារាសាស្ត្រសម្រាប់គ្រូនៃសាលាដេស្ទីតបន្ទាយមានជ័យ




តារាសាស្ត្រ គឺជាវិទ្យាមួយដែលគេប្រើសម្រាប់សិក្សាអំពីផ្កាយនៅក្នុងចក្រវាលមើលពីពេលវេលាដំណើរគោចររបស់ផ្កាយដោយទាក់ទងទៅនឹងទិស រដូវ ពេល និងម៉ោង។ វិទ្យានេះត្រូវបានមនុស្សយកមកប្រើប្រាស់ និងស្វែងយល់ជាយូរមកហើយ ជាពិសេសអ្នកដំណើរនៅតាមសមុទ្រ និងវាលខ្សាច់ដែលពឹងលើវិទ្យាមួយនេះជាចាំបាច់សម្រាប់រកទិសតំបន់។ ដោយឡែកសម្រាប់កម្មវិធីសិក្សាកម្រិតបឋមរហូតដល់វិទ្យាល័យក៏មានមុខវិទ្យាមួយនិយាយអំពីតារាសាស្ត្រនេះដែរ គឺផែនដីវិទ្យា។

ដើម្បីជួយលោកគ្រូ ឲ្យមានមូលដ្ឋានគ្រឹះកាន់តែច្បាស់លាស់អំពីផ្នែកតារាសាស្ត្រនេះសាលាដេស្ទីតសន្តសាវីយ៉េ ដែលមានទីតាំងស្ថិតនៅក្នុងភូមិភ្នំបាក់សង្កាត់ទឹកថ្លា ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ បានរៀបចំសិក្ខាសាលាមួយស្តីអំពីតារា-សាស្ត្រ ដែលមានការបង្ហាត់បង្ហាញដោយក្រុមសមាគមន៍តារាសាស្ត្រមកពីប្រទេសកូរ៉េប្រមាណជា៦នាក់ពីថ្ងៃទី១៧ ដល់២១ ខែកញ្ញា ឆ្នាំ២០១៨ដែលមានសិក្ខាកាមជាលោកគ្រូអ្នកគ្រូ របស់សាលាផ្ទាល់ប្រមាណជា២០នាក់។

បើតាមប្រសាសន៍របស់លោកប្រធានផ្នែករដ្ឋបាលនិងសហគមន៍សិក្សានៃសាលាដេស្ទីតបងប្រុសជួងជាម៉ូបានឲ្យដឹងថា ៖ ការសិក្សាអំពីតារាសាស្ត្រ គឺមិនមានភាពងាយស្រួលនោះទេប្រសិនបើមិនបានអនុវត្តជាក់ស្តែង ព្រោះវាពិបាកយល់ប្រសិនបើមិនមានការពន្យល់ និងបង្ហាញឲ្យបានល្អិតល្អន់នោះទេ។ លោកជាម៉ូបន្ថែមថា សាលាចង់ឲ្យលោកគ្រូអ្នកគ្រូទាំងអស់មានបទពិសោធថ្មីៗក្នុងការសិក្សាផ្នែកតារាសាស្ត្រនេះ ដោយមានការអនុវត្តផងនិងរៀនទ្រឹស្តីផងដើម្បីងាយស្រួលក្នុងការបង្រៀនសិស្សានុសិស្សរបស់ខ្លួនព្រោះគ្រូមានមូលដ្ឋានគ្រឹះស្រាប់។

អ្នកសម្របសម្រួលកម្មវិធីរូបនេះបានបន្ថែមទៀតថា ៖ការសិក្សានេះ គឺមានសារៈសំខាន់ណាស់ព្រោះនៅប្រទេសកម្ពុជា គឺមិនមានច្រើនទេកម្មវិធីសិក្សាតារាសាស្ត្រដែលមានឧបករណ៍គ្រប់គ្រាន់ សម្រាប់ការពិសោធបែបនេះ។ វាខុសគ្នានិងការសិក្សាដោយគ្រាន់តែអាន និងមើលរូបភាពតាមសៀវភៅផ្សេងៗ។

ចំណែកលោក ជឿង វ៉េតវៃ៣០ឆ្នាំជាគ្រូផ្នែកផែនដីវិទ្យានៃសាលាដេស្ទីត សន្តសាវីយ៉េនេះ បានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនថា ៖ លោកសប្បាយចិត្តព្រោះវាហាក់បីដូចជាប្លែកខ្លាំងសម្រាប់លោក។ ព្រោះលោកធ្លាប់តែធ្វើការបង្រៀនសិស្សដោយការស្វែងរកមេរៀនទៅតាមGoogle ឬតាមសៀវភៅរបស់ក្រសួង និងឯកសារផ្សេងៗហេតុនេះធ្វើឲ្យលោកមានការស្រពិចស្រពិលចំពោះការពន្យល់ដល់សិស្ស។ លោកវ៉េតបន្ថែមទៀតថា ៖ ក្រោយពេលដែលលោកបានចូលរួមសិក្ខាសាលានេះ គឺហាក់ដូចជាភ្លឺស្រឡះជាងពីមុនដែលលោកធ្លាប់តែធ្វើការស្រមៃរូបភាពផ្សេងៗទៅតាមមេរៀន តែមិនដែលបានឃើញផ្ទាល់តាមរយៈឧបករណ៍មីក្រូទស្សន៍បែបនេះ។ លោកបានរៀនច្រើនដូចជាការប្រើប្រាស់តេលេទស្សន៍ ការតំឡើងតេលេ-ទស្សន៍ ការបញ្ជារោបត ការកំណត់ទីតាំងភូមិសាស្ត្រ និងការមើលផែនទីតារាជាដើម។ លោក វ៉េតបន្ថែមថា វាពិបាកក្នុងការសិក្សាខ្លះៗព្រោះតែយើងមានភាសាផ្សេងគ្នា ហើយពាក្យប្រើក្នុងមេរៀន គឺសុទ្ធតែជាពាក្យបច្ចេកទេស តែដោយមានការជួយបកប្រែពីបងប្រុសនៅទីនោះ និងការខិតខំព្យាយាមតាមដានមេរៀន ដែលគ្រូកូរ៉េបង្ហាញធ្វើឲ្យមានភាពល្អប្រសើរឡើងវិញ។

លោកគ្រូរូបនេះសង្ឃឹមថាខ្លួននឹងមានទំនុកចិត្ត និងមានការពន្យល់កឲ្យបានក្បោះក្បាយជាងមុនតាមអ្វីដែលលោកទទួលបានសិក្ខាសាលានេះ។

លោកជាម៉ូបន្ថែមទៀតថា ៖ ប្រសិនបើកម្មវិធីសិក្ខាសាលាផ្នែកតារាសាស្ត្រនេះជោគជ័យ ខាងលាសាដេស្ទីតនឹងរៀបចំគម្រោងបង្កើតជាសមាគមន៍តារាសាស្ត្រដូចនៅប្រទេសកូរ៉េដែរគឺដើម្បីបង្កើនចំណេះដឹងនេះទៅដល់កុមារ និងយុវជនឲ្យកាន់តែល្អប្រសើរថែមទៀត។

សព្វថ្ងៃសាលាដេស្ទីតសន្តសាវីយ៉េខេត្តបន្ទាយមានជ័យមានសិស្សសរុប ៤៤០នាក់ក្នុងនោះ គឺមានកម្រិតមតេយ្យសិក្សា៣កម្រិត បឋមសិក្សាពីទី១ដល់ថ្នាក់ទី៤។ កម្រិតអនុវិទ្យាល័យពីថ្នាក់ទី៧ និងទី៨។ ដោយឡែកនៅខ្វះថ្នាក់ទី៥ និងថ្នាក់ទី៦នៅឡើយទេ ព្រោះខាងសាលាមានបញ្ហាខ្វះៗតែនៅឆ្នាំក្រោយសាលានេះនឹងធ្វើការពង្រីករហូតដល់ទី១២។ ដោយ៖ រឿន ស្រីម៉ាច

# ព្រះសហគមន៍អ្នកលឿងអប់រំយុវជនអំពីអគ្គសញ្ញាអាពាហ៍ពិពាហ៍



យុវជន យុវនារីចំនួន៣០នាក់បានចំណាយពេលវេលាចំនួន១០ពេលរៀងរាល់ថ្ងៃអាទិត្យក្រោយអភិបូជា ដើម្បីស្វែងយល់អំពីអគ្គសញ្ញាអាពាហ៍ពិពាហ៍ ដែលរៀបចំដោយ ព្រះវិហារ គ្រួសារដ៏វិសុទ្ធនៃព្រះសហគមន៍កាតូលិក អ្នកលឿង។

វគ្គអប់រំនេះ ណែនាំដោយលោកបូជា-ចារ្យ សេរ៉ាល់ វ៉ូហ្សាំង ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិកមួយនេះ និងសហការជាមួយអង្គការ Karol &Setha ចាប់ពីថ្ងៃទី១៧ ខែឧសភា ដល់ថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ២០១៨នេះ។ សិក្ខាកាមទាំងអស់បានទទួលវិញ្ញាបណ្ណបត្រ បញ្ជាក់ការសិក្សា នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៨កន្លងទៅនេះ។

បើតាមគណៈកម្មការរៀបចំនៃវគ្គអប់រំនេះបានឲ្យដឹងថា វគ្គនេះមានគោលបំណងយ៉ាងពិសេស គឺអប់រំយុវជន មុនពួកគេរៀបអាពាហ៍ពិពាហ៍ ឲ្យគេចេះត្រៀមខ្លួនទទួលយកគូរស្រករ ដែលគេនឹងរៀបការជាមួយ។ ចេះរៀបចំផែនការគ្រួសារ ដែលអាចរស់នៅប្រកបដោយសេចក្តីសុខសាន្តនិងសភមង្គលក្នុងគ្រួសារ។ ព្រោះថា តំបន់អ្នកលឿង ភាគច្រើនយុវជន ដែលរៀបការគឺមាតាបិតាជាអ្នកជ្រើសរើសគូរស្រករឲ្យនិងតម្រូវឲ្យគេរៀបការជាមួយ មនុស្សដែលគេមិនដែលស្គាល់។ គូរស្រករភាគច្រើនបានលែងលះគ្នា។

ក្នុងរយៈពេល១០ពេលនេះសិក្ខាកាមទាំងអស់បានសិក្សាលើប្រធានបទ ៖ ស្វែងយល់អំពីអគ្គសញ្ញាអាពាហ៍ពិពាហ៍ក្នុងព្រះសហគមន៍កាតូលិក ស្វែងយល់អំពីអាពាហ៍ពិពាហ៍តាមច្បាប់រដ្ឋ និងតាមច្បាប់ព្រះសហគមន៍កាតូលិក អំពីគ្រួសារជាកោសិកាក្នុងសង្គម កំហឹង និងការគ្រប់គ្រងកំហឹង ជីវិតតាមផ្លូវវិញ្ញាណរបស់ក្រុមគ្រួសារក្នុងជំនឿកាតូលិក វិធីសាស្ត្រអប់កូន ការត្រៀមខ្លួនរៀបអាពាហ៍ពិពាហ៍ និងអំពីជីវិតផ្លូវភេទ និងការពន្យាកំណើត ទាំងនេះដែលអប់រំដោយអង្គការ Karol & Setha។

លូ រ៉ាវែនធី សិក្ខាកាមមួយរូបដែលបានចូលទទួលការអប់រំរយៈ១០ពេលនេះមក គេបានចាប់អារម្មណ៍ថា គេបានរៀនច្រើននិងយល់ដឹងអំពីការត្រៀមខ្លួន មុនរៀបការព្រមទាំងយល់ដឹងអំពីការរៀបចំផែនការគ្រួសារនាពេលខាងមុខផងដែរ។ លោកអរគុណដល់លោកបូជាចារ្យ និងព្រះសហគមន៍ ដែលបានរៀបចំវគ្គអប់រំនេះ។

ព្រះវិហារគ្រួសារដ៏វិសុទ្ធនៃព្រះសហ-គមមន៍កាតូលិកអ្នកលឿង ស្ថិតនៅក្នុងភូមិភាគកំពង់ចាម ដែលមានគ្រីស្តបរិស័ទប្រមាណជាង៣០០គ្រួសារ។

ដោយ៖ រឿន ស្រីម៉ាច

# វិទ្យាស្ថានសន្តប៉ូល
## Saint Paul Institute

**ឱកាសទទួលបានអាហារូបករណ៍ពិសេសពីវិទ្យាស្ថានសន្តប៉ូល ចាប់ពី ២៥% ដល់១០០% សម្រាប់អ្នកធ្លាក់ និងជាប់បាក់ឌុបទាំងអស់ ថែមទាំងមានផ្តល់ជូនការរៀនវគ្គបំប៉នភាសាអង់គ្លេស និងកុំព្យូទ័រដោយឥតគិតថ្លៃផងដែរ។**

**កាលបរិច្ឆេទចូលរៀនវគ្គបំប៉ន ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨**

### ថ្នាក់បរិញ្ញាបត្រ

- ព័ត៌មានវិទ្យា
- អក្សរសាស្ត្រអង់គ្លេស
- គ្រប់គ្រងទេសចរណ៍
- កសិកម្ម
- សង្គមកិច្ច

### ថ្នាក់បរិញ្ញាបត្ររងបច្ចេកទេស

- អភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រ
- គ្រប់គ្រងប្រព័ន្ធ និងបណ្ដាញកុំព្យូទ័រ
- ភាសាអង់គ្លេស
- សណ្ឋាគារ និងបដិសណ្ឋារកិច្ច
- ផលិតកម្មដំណាំឈើហូបផ្លែ និងបន្លែ
- ជំនាញកែច្នៃចំណីអាហារ
- ប្រព័ន្ធកសិកម្មចម្រុះ
- វេជ្ជសាស្ត្រសត្វ



**ចុះឈ្មោះចូលរៀនចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ**

អាសយដ្ឋាន៖ ផ្លូវជាតិលេខ៣ ភូមិអង្គគគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ ខាងជើងផ្សារអង្គតាសោម ៣គីឡូម៉ែត្រ

ទូរស័ព្ទលេខ៖ ០៣២ ៦៣ ៩០ ០០៣ | Saint Paul Institute | http://spi.edu.kh/

# រូបភាពព្រះសហគមន៍ប្រចាំខែ



សិក្ខាសាលាព្រះគម្ពីរសម្រាប់ពន្លកថ្មី ដែលរៀបចំដោយគណៈកម្មការព្រះគម្ពីរកាតូលិកកម្ពុជា នៅកំពង់ចាមក្រុង



អធិដ្ឋានសូត្រផ្គាំតាមមាលាថ្វាយព្រះនាងម៉ារី នៅព្រះសហគមន៍កាតូលិកត្រែងត្រយឹង



ក្រុមលោកបូជាចារ្យបម្រើព្រះសហគមន៍ភូមិភាគបាត់ដំបង



ក្រុមលោកបូជាចារ្យជាតិកម្ពុជាទាំងបីភូមិភាគ



កម្មវិធីអធិដ្ឋានសូត្រផ្គាំតាមមាលា តាមផ្ទះតាមផ្ទះរបស់
គ្រីស្តបរិស័ទ នៃព្រះសហគមន៍កាតូលិកសន្តមីកាអែលកំពង់សោម



លោកអភិបាល អែនរីកេ ហ្វីកាវេជូ ប្រតិភូនៃកម្ពុជា អញ្ជើញចូលរួមមហាសន្និបាត លោកអភិបាលឆ្នាំ២០១៨
ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ នៅទីក្រុងរ៉ូម ថ្ងៃទី០២-២៩ ខែតុលា ឆ្នាំ២០១៨



សិក្ខាសាលាបំប៉នសមត្ថភាពគ្រូមេត្តយ្យនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ


Radio Veritas Asia
Khmer Service
RADIO VERITAS ASIA-KHMER SERVICE

# វិទ្យុវើរីតាស់អាស៊ីខេមរភាសា

## សំឡេងពីព្រះសហគមន៍កាតូលិកកម្ពុជា

**វិទ្យុវើរីតាស់អាស៊ី ជាខេមរភាសា ផ្សាយរៀងរាល់ថ្ងៃ លើស្ថានីយ៍វិទ្យុ FM នៅភ្នំពេញ និងតាមបណ្ដាខេត្តមួយចំនួន តាមពេលវេលាដូចខាងក្រោម៖**

| | | |
|---|---|---|
| ភ្នំពេញ | : FM 103 Mhz | ម៉ោង ៨:០០- ៩:០០ យប់ |
| បាត់ដំបង | : FM 91 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងសៀមរាប | : FM 100.5 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |
| ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | : FM 103.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងកំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ព្រះសីហនុ | : FM 100.5 Mhz | ម៉ោង ៦:០០- ៧:០០ យប់ |
| ក្រុងកំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |

- លោកអ្នកក៏អាចស្តាប់កម្មវិធីផ្សាយរបស់វិទ្យុវើរីតាស់អាស៊ី ខេមរភាសានៅលើគេហទំព័រ www.rvakhmer.com, www.catholiccambodia.org

- លោកអ្នក ក៏អាច Follow face book ផ្លូវការរបស់យើង https://www.facebook.com/RVAKHMER/

**✣ តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង**

លោកអ្នកអាចស្តាប់កម្មវិធីវិទ្យុវើរីតាស់អាស៊ីជាភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ **Smart Phone** ដែលប្រើប្រព័ន្ធ **Android** ឬប្រព័ន្ធ **IOS** ដោយគ្រាន់តែចូលទៅកាន់ **Play Store** ឬ **App Store** វាយពាក្យ **Radio Veritas Asia** រួច **Download** កម្មវិធីនោះដោយស្វែងរកប៊ូតុង **(Khmer Live Audio)** ។

Radio Veritas Asia
Khmer Live audio

ឬ តាមរយៈវេបសាយ៖ http://rvakhmer.com